សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economies

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការចាត់ចែងរក្សាការពារលើអចលនវត្ថុ

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ៖

និស្សិតឈ្មោះ៖ **គួច សុវណ្ណាវរៈ**

**ប្រាក់ ស្រីនិច**

សាស្ត្រាចារ្យណែនាំ៖

លោក **ហេង មូរ៉ា**

ថ្នាក់បរិញ្ញាបត្រ៖ **នីតិសាស្ត្រ**

ជំនាន់ទី៖ ២២

ឆ្នាំសិក្សា៖ ២០១៨

ឆ្នាំសរសេរសារណា៖ ២០២២

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **គួច សុវណ្ណារិទ្ធ** នាងខ្ញុំឈ្មោះ **ប្រាក់ ស្រីនិច** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២២ ក្នុងឆ្នាំសិក្សា២០២១-២០២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

## សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ

**លោកឪពុក អ្នកម្តាយ** លោកទាំងទ្វេបានផ្តល់កំណើតដល់រូបយើងខ្ញុំ រួមទាំងការខិតខំប្រឹងប្រែងគ្រប់សព្វបែបយ៉ាង ចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មាន ប្រៀនប្រដៅ ប្រកបដោយទឹកចិត្តព្រហ្មវិហារធម៌ មេត្តា ករុណា មុទិតា និងឧបេក្ខា។ ទន្ទឹមនឹងនេះ លោកដ៏មានគុណទាំងពីរ បានខិតខំស្វះស្វែង ពុះពារជំនះ រាល់គ្រប់ឧបសគ្គ ដោយមិនខ្លាចនឿយហត់ដើម្បី ផ្គត់ផ្គង់ ជ្រោមជ្រែង ជម្រុញឱ្យរូបយើងខ្ញុំទទួលបានការសិក្សា ក្រេបជញ្ជក់យកចំណេះវិជ្ជា រហូតដល់បញ្ចប់កម្រិតថ្នាក់ឧត្តមសិក្សាដោយជោគជ័យ។

## សូមគោរពនិងថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅជូន

**ឯកឧត្តម សាកលវិទ្យាធិការ** សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ព្រមទាំងលោក លោកស្រី សាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានបង្ហាត់បង្រៀន និងណែនាំនូវផ្លូវល្អៗដល់យើងខ្ញុំជាសិស្សនិស្សិត។ ជាពិសេស លោក/លោកស្រី និងសាស្ត្រាចារ្យ ដែលបានយកចិត្តទុកដាក់ក្នុងការផ្តល់ចំណេះដឹងដល់យើងខ្ញុំដោយមិនខ្លាចនឿយហត់ និងការជម្រុញផ្នែកស្មារតីឱ្យយើងខ្ញុំខិតខំរៀនសូត្រ ក្រេបជញ្ជក់យកចំណេះវិជ្ជា។

ជាពិសេស សូមគោរពអរគុណចំពោះ **លោកសាស្ត្រាចារ្យ ហេង ម៉ូរ៉ា** បានចំណាយពេលវេលាដ៏មានតម្លៃទទួលបន្ទុកក្នុងការដឹកនាំសារណារបស់យើងខ្ញុំ ដែលលោកសាស្ត្រាចារ្យ បានខិតខំអស់ពីកម្លាំងកាយចិត្តក្នុងការផ្តួចផ្តើមផ្តល់ជាគំនិតជាបន្តបន្ទាប់ និងជម្រុញណែនាំ លើកទឹកចិត្ត ត្រួតពិនិត្យ កែលម្អជាច្រើនដល់រូបយើងខ្ញុំចំពោះការសិក្សាស្រាវជ្រាវ និងចងក្រងនូវអត្ថបទសារណានេះឡើង រហូតដល់បានបញ្ចប់ជាស្ថាពរ និងប្រកបដោយលទ្ធផលវិជ្ជមាន។

ជាកិច្ចបញ្ចប់ យើងខ្ញុំសូមបួងសួងដល់ លោកឪពុក អ្នកម្តាយ ព្រមទាំងថ្នាក់ដឹកនាំសាកលវិទ្យាល័យ លោក/លោកស្រីសាស្ត្រាចារ្យ លោកសាស្ត្រាចារ្យដឹកនាំសារណា សូមឱ្យជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីឆ្លងកាត់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ រយៈពេល៤ឆ្នាំ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច កន្លងមកយើងខ្ញុំពិតជាទទួលបានចំណេះដឹងយ៉ាងច្រើនហូរហែរពីសំណាក់សាស្ត្រាចារ្យ ចាប់តាំងពីឆ្នាំសិក្សាថ្នាក់មូលដ្ឋាន រហូតដល់បច្ចុប្បន្ន។ ក្នុងអំឡុងនៃពេលសិក្សាយើងខ្ញុំ បានរៀបចំកិច្ចការស្រាវជ្រាវ និងចងក្រងទៅលើឯកសារនានាជាច្រើន ដែលវាជាមូលដ្ឋានសម្រាប់យើងខ្ញុំ ចំពោះមូលហេតុដែលយើងខ្ញុំជ្រើសរើសប្រធានបទ ការចាត់ចែងរក្សាការពារលើអចលនវត្ថុ នេះឡើងដោយហេតុថាប្រធានបទនេះគួរឱ្យចាប់អារម្មណ៍ មើលទៅមានលក្ខណៈសាមញ្ញ ប៉ុន្តែបើសិក្សាឱ្យស៊ីជម្រៅ គឺថាមានលក្ខណៈលំបាក និងស្មុគស្មាញជាខ្លាំង។

គោលបំណងដែលយើងខ្ញុំចងក្រងប្រធានបទសារណានេះឡើង ព្រោះមើលឃើញថាខ្លឹមសារនៅក្នុងដំណាក់នីមួយៗពិតជាមានសារៈសំខាន់សម្រាប់ការអនុវត្តនាពេលបច្ចុប្បន្ន ជាពិសេសក្នុងជីវភាពរស់នៅប្រចាំថ្ងៃជាងនេះទៅទៀតក្រមនីតិវិធីរដ្ឋប្បវេណី បានផ្ដោតជាសំខាន់ទៅលើដំណាក់កាល នៃនីតិវិធីចាត់ចែងរក្សាការពារម្យ៉ាងវិញទៀតក្នុងនាមយើងជាសិស្សនិស្សិតនីតិសាស្ត្រ គួរតែសិក្សាស្វែងយល់ឱ្យបានច្បាស់អំពីប្រធានបទនេះដើម្បីជាប្រយោជន៍នៅពេលដែលជួបបញ្ហាជាក់ស្តែងក្នុងពេលណាមួយ ពេលនោះផងដែរ អ្នកទាំងអស់គ្នានឹងយល់ឃើញថា ការចាត់ចែងរក្សាការពារគួរតែអនុវត្តដោយរបៀបណាខ្លះ ហើយនីតិវិធីនេះមានផលប្រយោជន៍ក្នុងការដោះស្រាយវិវាទដែលកើតមានជាក់ស្តែងរបស់អ្នកទាំងអស់គ្នា ឬក្នុងអំឡុងពេលដែលអ្នកទាំងអស់គ្នាចេញប្រកបការងារក្នុងវិស័យច្បាប់ ឬស្ថានភាពណាមួយដែលបារម្ភថានឹងមានការខូចខាត ឬខូចប្រយោជន៍អ្វីមួយក្នុងពេលអនាគត។

តាមរយៈប្រធានខាងលើនេះយើងខ្ញុំសង្ឃឹមថា នឹងផ្តល់នូវអត្ថប្រយោជន៍ និងជាប្រយោជន៍តូចមួយក្នុងការជួយដល់សិស្សនិស្សិតទាំងឡាយ ដែលចង់សិក្សាស្រាវជ្រាវ ឱ្យមានភាពកាន់តែស៊ីជម្រៅ និងទទួលបាននូវចំណេះដឹង បង្កើនសមត្ថភាពបន្ថែម បន្ទាប់ពីបានអានអត្ថបទដែលយើងខ្ញុំបានតាក់តែងខាងលើនេះ។

ជាកិច្ចបញ្ចប់ យើងខ្ញុំសូមធ្វើការអភ័យទោសរាល់កំហុសខុសឆ្គងដោយអចេតនាដែលកើតមានឡើងតាមរយៈកំហុសអក្ខរាវិរុទ្ធ ឃ្លាឃ្លោង ពាក្យពេចន៍មិនសមរម្យ ការខ្វះខាតអត្ថន័យជាដើម។ យើងខ្ញុំរីករាយនឹងទទួលរាល់ពាក្យកែលម្អ ការរិះគន់ដើម្បីស្ថាបនា ពីសំណាក់មិត្តអ្នកអាន ដោយសេចក្តីគោរព និងរីករាយសោមនស្ស។

# មាតិកា


ទំព័រ

**សេចក្ដីផ្ដើម** .......... ១

## ជំពូកទី១
## សញ្ញាណទូទៅនៃការចាត់ចែងរក្សាការពារលើអចលនវត្ថុ

**ផ្នែកទី១៖ គោលគំនិតនៃការចាត់ចែងរក្សាការពារលើអចលនវត្ថុ** .......... ៣

១.១ និយមន័យនៃការចាត់ចែងរក្សាការពារ .......... ៤

១.២ ទស្សនៈរួមនៃការចាត់ចែងរក្សាការពារ .......... ៤

**ផ្នែកទី២៖ ភាពចាំបាច់ និងលក្ខណៈពិសេសនៃការចាត់ចែងរក្សាការពារ** .......... ៤

២.១ ភាពចាំបាច់នៃការចាត់ចែងរក្សាការពារ .......... ៤

២.២ លក្ខណៈពិសេសនៃការចាត់ចែងរក្សាការពារ .......... ៥

## ជំពូកទី២
## ដំណើរការនីតិវិធីនៃការចាត់ចែងរក្សាការពារលើអចលនវត្ថុ

**ផ្នែកទី១៖ សិទ្ធិនៃការចាត់ចែងរក្សាការពារ** .......... ៨

១.១ ករណីការរឹបអូសជាបណ្ដោះអាសន្ន .......... ៨

១.២ ករណីការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ .......... ៨

១.៣ ករណីការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន .......... ៩

**ផ្នែកទី២៖ ការដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ** .......... ៩

២.១ ការសរសេរពាក្យសុំ .......... ១០

២.១.១ ចំណុចត្រូវសរសេរក្នុងពាក្យសុំ .......... ១០

២.២ ស្ថាប័នមានសមត្ថកិច្ចចំពោះការចាត់ចែងរក្សាការពារ .......... ១១

២.២.១ តុលាការដែលមានសមត្ថកិច្ចលើបណ្ដឹងអង្គសេចក្ដី .......... ១១

២.២.២ តុលាការមានសមត្ថកិច្ចលើវត្ថុដែលនឹងត្រូវរឹបអូស ឬកម្មវត្ថុនៃវិវាទ .......... ១២

២.៣ សោហ៊ុយនៃការចាត់ចែងរក្សាការពារ .......... ១២

២.៣.១ ពន្ធដាក់ពាក្យសុំ .......... ១២

២.៣.២ ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ .......... ១២

២.៣.៣ បន្ទុកនៃប្រាក់ប្រដាប់ក្ដី .......... ១៣

២.៤ ការវិនិច្ឆ័យ និងការត្រួតពិនិត្យលើពាក្យសុំ ........ ១៣
២.៤.១ ការពិនិត្យពាក្យសុំ ........ ១៣
២.៤.២ ការចេញដីកាសម្រេចចាត់ចែងរក្សាការពារ ........ ១៣
**ផ្នែកទី៣៖ ប្រភេទនៃដីកាសម្រេចរក្សាការពារ** ........ ១៤
៣.១ លក្ខខណ្ឌនៃការចេញដីកាសម្រេចរក្សាការពារ ........ ១៤
៣.២ ចំណុចដែលត្រូវសរសេរនៅក្នុងដីកាសម្រេចរក្សាការពារ ........ ១៤
៣.២.១ ភាពចាំបាច់ដើម្បីបញ្ជាក់រឿងក្ដី ........ ១៤
៣.២.២ ការសរសេរបញ្ជាក់នូវកម្មវត្ថុនៃដីកាសម្រេចរក្សាការពារ ........ ១៥
៣.៣ ប្រាតិភោគ ........ ១៥
៣.៣.១ គោលបំណងនៃប្រាតិភោគ ........ ១៥
៣.៣.២ ចំនួននៃប្រាតិភោគ ........ ១៦
៣.៣.៣ វិធីនៃការដាក់ប្រាតិភោគ ........ ១៧
៣.៤ ការបញ្ជូនដីកាសម្រេចរក្សាការពារ ........ ១៧
៣.៤.១ ដីកាសម្រេចបង្គាប់ឱ្យរក្សាការពារ ........ ១៧
៣.៤.២ ដីកាសម្រេចលើកចោលពាក្យសុំ ........ ១៨

## ជំពូកទី៣
## ការអនុវត្តរក្សាការពារ

**ផ្នែកទី១៖ ប្រភេទនៃការអនុវត្តចាត់ចែងរក្សាការពារ** ........ ១៩
១.១ ការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ........ ១៩
១.១.១ ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ........ ១៩
១.១.២ ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុ ........ ២០
១.១.៣ ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ........ ២១
១.១.៤ ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះនាវា ........ ២១
១.២ ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន ........ ២២
១.២.១ នីតិវិធីនៃការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន ........ ២២
១.២.២ អានុភាពនៃការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន ........ ២៣

១.៣ ស្ថាប័នមានសមត្ថកិច្ចក្នុងការអនុវត្តដីកាសម្រេចរក្សាការពារ ..... ២៣
១.៣.១ ស្ថាប័នអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ..... ២៤
១.៣.២ ស្ថាប័នអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ..... ២៤
១.៣.៣ ស្ថាប័នអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ ..... ២៤
១.៣.៤ ស្ថាប័នអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះនាវា ..... ២៤
**ផ្នែកទី២៖ ការដាក់ពាក្យសុំឱ្យអនុវត្តរក្សាការពារ** ..... ២៥
២.១ ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ ..... ២៥
២.២ សោហ៊ុយនៃការអនុវត្តរក្សាការពារ ..... ២៥
២.២.១ ពន្ធដាក់ពាក្យសុំ ..... ២៥
២.២.២ សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ ..... ២៦
២.៣ អំឡុងពេលនៃការដាក់ពាក្យសុំឱ្យអនុវត្តដីកាសម្រេចរក្សាការពារ ..... ២៦
**ផ្នែកទី៣៖ ឧបាស្រ័យចំពោះដីកាសម្រេចរក្សាការពារ និងការអនុវត្តរក្សាការពារ** ..... ២៦
៣.១ ការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ..... ២៧
៣.១.១ ការទាញហេតុផលដោយផ្ទាល់មាត់ ..... ២៧
៣.១.២ ការបញ្ចប់ការវិនិច្ឆ័យចំពោះការតវ៉ា ..... ២៧
៣.១.៣ ការចេញដីកាសម្រេចចំពោះការតវ៉ាលើដីកាសម្រេចរក្សាការពារ ..... ២៨
៣.២ ការតវ៉ាចំពោះការអនុវត្តរក្សាការពារ ..... ២៨
៣.២.១ បណ្តឹងតវ៉ារបស់តតិយជន ..... ២៨
៣.២.២ សមត្ថកិច្ចចំពោះដីកាសម្រេចរក្សាការពារ ..... ២៨
៣.៣ ការសុំឱ្យលុបចោលដីកាសម្រេចរក្សាការពារ ..... ២៩
៣.៣.១ ការទាញហេតុផលដោយយផ្ទាល់មាត់ ..... ២៩
៣.៣.២ ការផ្អាកលើដីកាសម្រេចរក្សាការពារ ..... ២៩
៣.៤ បណ្តឹងជំទាស់ ..... ៣០
៣.៤.១ មូលហេតុនៃបណ្តឹងជំទាស់ ..... ៣០
៣.៤.២ ការទាញហេតុផលដោយផ្ទាល់មាត់ ..... ៣០
៣.៤.៣ ការបញ្ចប់ការវិនិច្ឆ័យចំពោះបណ្តឹងជំទាស់ ..... ៣០
៣.៤.៤ អំឡុងពេលនៃបណ្តឹងជំទាស់ ..... ៣១

## ជំពូកទី៤
## បញ្ហាប្រឈម និងដំណោះស្រាយ

**ផ្នែកទី១៖ បញ្ហាប្រឈម** ........ ៣២
១.១ ភាពខ្វះចន្លោះប្រហោងនៃច្បាប់ ........ ៣២
១.២ ការយល់ដឹងផ្នែកច្បាប់របស់ប្រជាពលរដ្ឋនៅមានកំរិត ........ ៣៣
១.៣ កង្វះខាតអាជ្ញាសាលា និងផលវិបាកក្នុងការអនុវត្តរក្សាការពារ ........ ៣៣
១.៤ ការជាន់សមត្ថកិច្ចរវាងព្រះរាជអាជ្ញា និងអាជ្ញាសាលា ........ ៣៤
១.៥ ការធ្វេសប្រហែសរបស់មន្ត្រីជំនួយក្នុងការអនុវត្តរក្សាការពារ ........ ៣៤
១.៦ ការចាត់ចែងរក្សាការពារខុសអចលនវត្ថុ ........ ៣៥
**ផ្នែកទី២៖ ដំណោះស្រាយ** ........ ៣៦
២.១ ការបង្កើតលិខិតបទដ្ឋានគតិយុត្តឱ្យបានច្រើន ........ ៣៧
២.២ ការផ្សព្វផ្សាយច្បាប់ជាសាធារណៈ ........ ៣៧
២.៣ ការជ្រើសសិស្សអាជ្ញាសាលា និងកិច្ចសហការមន្ត្រីជំនួយអនុវត្តរក្សាការពារ ........ ៣៧
២.៤ ការកំណត់សមត្ថកិច្ចរបស់ព្រះរាជអាជ្ញា និងអាជ្ញាសាលា ........ ៣៨
២.៥ ការយកចិត្តទុកដាក់របស់មន្ត្រីជំនួយក្នុងការអនុវត្តរក្សាការពារ ........ ៣៩
២.៦ ការកំណត់ឱ្យបានច្បាស់អត្តសញ្ញាណកម្មវត្ថុនៃការចាត់ចែងរក្សាការពារ ........ ៣៩
**សេចក្តីសន្និដ្ឋាន** ........ ៤១
**អនុសាសន៍** ........ ៤៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នាពេលបច្ចុប្បន្ននេះ បុគ្គលគ្រប់រូបរមែងមានការប្រាស្រ័យទាក់ទងគ្នាយ៉ាងសកម្មនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃក្នុងគោលបំណងបង្កើនសេដ្ឋកិច្ច ផលប្រយោជន៍ ហើយទំនាក់ទំនងទាំងអស់នេះហើយទើបបង្កើតឱ្យមានកាតព្វកិច្ចរវាងគ្នាទៅវិញទៅមក។ ចំពោះការបំពេញកាតព្វកិច្ចរបស់បុគ្គលនីមួយៗ គឺត្រូវធ្វើឡើងស្របទៅតាមការសន្យាដោយផ្ទាល់មាត់ កិច្ចសន្យា ឬតាមទំនៀមទម្លាប់នៃតំបន់ដែលពួកគេរស់នៅ "ហើយបុគ្គលម្នាក់ៗត្រូវប្រតិបត្តិតាមកិច្ចសន្យាដោយគោរពនូវសិទ្ធិ" និងផលប្រយោជន៍របស់ភាគីម្ខាងទៀតដោយអនុវត្តកាតព្វកិច្ចកើតមានឡើង ការខូចខាតរវាងគ្នានិងគ្នា ដែលនាំឱ្យខាតបង់ផលប្រយោជន៍ទាំងពេលវេលា និងប្រាក់កាស។ ប៉ុន្តែប្រសិនបើមានករណីភាគីណាម្ខាងមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ហើយបំពានកិច្ចសន្យាដែលជាហេតុនាំឱ្យមានការខូចខាត ឬខូចប្រយោជន៍ ដល់ភាគីម្ខាងទៀតនៃកិច្ចសន្យានោះ វិវាទនឹងកើតមានឡើង។ ស្របជាមួយគ្នានេះដែរ ប្រសិនជាវិវាទដែលកើតឡើងនោះ គូភាគីអាចសម្របសម្រួលគ្នាបាន វាមិនមែនជាបញ្ហាចោទនោះទេ។ ផ្ទុយទៅវិញបើវិវាទនោះ មិនអាចដោះស្រាយបានភាគីដែលត្រូវបានគេបំពាន អាចធ្វើការដាក់ពាក្យបណ្តឹងទៅតុលាការដែលមានសមត្ថកិច្ច ដើម្បីដោះស្រាយទាមទារសំណងនៃការខូចខាត ដែលកើតមានមកលើខ្លួននោះបាន។ តើចំពោះដំណោះស្រាយត្រូវបានធ្វើឡើងដោយរបៀបណាខ្លះ? ចំពោះដំណោះស្រាយវិវាទស្របតាមក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ តុលាការដោះស្រាយវិវាទទៅតាមប្រភេទនៃរឿងក្តី ដូចជានីតិវិធីបណ្តឹងអង្គសេចក្តី នីតិវិធីចាត់ចែងរក្សាការពារ និងនីតិវិធីអនុវត្តដោយបង្ខំ។ ប៉ុន្តែក្នុងប្រធានបទខាងលើនេះ យើងខ្ញុំចង់បង្ហាញអំពីនីតិវិធីនៃការចាត់ចែងរក្សាការពារ ឬអាចនិយាយម្យ៉ាងទៀតបានថានីតិវិធីមុនបណ្តឹងអង្គសេចក្តី ដែលវាគឺជានីតិវិធីដ៏សំខាន់មួយក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ក្នុងគោលបំណងការពារសិទ្ធិ និងផលប្រយោជន៍របស់ម្ចាស់បំណុលដោយម្ចាស់បំណុលមានសិទ្ធិក្នុងការប្រើប្រាស់វិធានរក្សាការពារនេះ ក្នុងទំហំដែលច្បាប់បានកម្រិតដើម្បីហាមឃាត់កូនបំណុលចាត់ចែង លក់ដូរ ផ្ទេរ បញ្ចាំ ប្រទានកម្មទៅឱ្យតតិយជនទម្រាំតែមានសាលក្រម ឬសាលដីកាបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ប៉ុន្តែទោះជាយ៉ាងណាកូនបំណុល ក៏អាចតវ៉ាបានដែលក្នុងករណីដែលម្ចាស់បំណុលបានប្រើប្រាស់សិទ្ធិដោយបំពាន និងប៉ះពាល់សិទ្ធិស្របច្បាប់របស់ខ្លួនជាខ្លាំងនោះ។ នីតិវិធីនៃការចាត់ចែងរក្សាការពារ គឺអនុវត្តឡើងដើម្បីទប់ស្កាត់ការលក់ ឬការផ្ទេរ ទ្រព្យសម្បត្តិទៅឱ្យតតិយជនដើម្បីគេចវេសពីការសងដល់ម្ចាស់បំណុល តាមរយៈច្បាប់ ហើយក៏ជាយន្តការពិសេស មួយសម្រាប់ការពារនូវអំពើទាំងឡាយណាដែលភាគីយល់ថា មានការលំបាក ឬ ជាតម្រូវការដោយរៀបចំទប់ស្កាត់ ឬរារាំង នូវសកម្មភាពដែលប៉ះពាល់សិទ្ធិ និងផលប្រយោជន៍ភាគីដោយប្រការណាមួយជាមុននោះ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដូចម្តេចទៅដែលហៅថា ការចាត់ចែងរក្សាការពារលើអចលនវត្ថុ? ហើយតើការចាត់ចែងរក្សាការពារលើអចលនវត្ថុអាចធ្វើឡើងទៅបានដោយបំពេញនូវ លក្ខខណ្ឌ និងនីតិវិធីអ្វីខ្លះ?

តើការចាត់ចែងរក្សាការពារលើអចលនវត្ថុជួបប្រទះនូវបញ្ហាប្រឈម អ្វីខ្លះ? ហើយមានដំណោះស្រាយបែបណាខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ចំពោះការស្រាវជ្រាវប្រធានបទខាងលើ គឺដើម្បីចូលរួមចំណែកក្នុងការពង្រឹងវិស័យច្បាប់ឱ្យកាន់តែមានភាពរីកចម្រើន និងស្វែងយល់ឱ្យបានស៊ីជម្រៅអំពីនីតិវិធីនៃការចាត់ចែងរក្សាការពារ និងចងក្រងទុកជាឯកសារដើម្បីចែករំលែកទៅដល់បណ្តាលអ្នកសិក្សាទាំងឡាយដែលចង់យល់ដឹងអំពីប្រធានបទខាងលើនេះ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

វិសាលភាពនៃនីតិវិធីចាត់ចែងរក្សាការពារ មានលក្ខណៈធំទូលាយណាស់ ហើយប្រធានបទនេះផ្តោតសំខាន់ទៅលើទ្រឹស្តីនៃច្បាប់ ដែលបានបញ្ញត្តិស្របទៅតាមក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី និងច្បាប់ពាក់ព័ន្ធដូចជា ព្រះរាជក្រឹត្យ អនុវត្តក្រឹត្យ ប្រកាស ឬឯកសារពាក់ព័ន្ធផ្សេងៗទៀត ហើយជាពិសេសនោះគឺសិក្សាទៅលើការអនុវត្តជាក់ស្តែងចំពោះសំណុំរឿងរក្សាការពារ របស់សាលាដំបូងរាជធានីភ្នំពេញ និងសាលាឧទ្ធរណ៍ភ្នំពេញ ក្នុងឆ្នាំ២០២១ ដល់ឆ្នាំ២០២២។

## ៥. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ចំពោះប្រធានបទ "**ការចាត់ចែងរក្សាការពារលើអចលនវត្ថុ**" នេះត្រូវបានរៀបចំ និងចងក្រងឡើងដោយបែងចែកជាបួនជំពូកធំៗ រួមមានដូចខាងក្រោម៖

ជំពូកទី១៖ សញ្ញាណទូទៅនៃការចាត់ចែងរក្សាការពារលើអចលនវត្ថុ

ជំពូកទី២៖ ដំណើរការនីតិវិធីនៃការចាត់ចែងរក្សាការពារលើអចលនវត្ថុ

ជំពូកទី៣៖ ការអនុវត្តរក្សាការពារ

ជំពូកទី៤៖ បញ្ហាប្រឈម និងដំណោះស្រាយ

# ជំពូកទី១
# សញ្ញាណទូទៅ
# នៃការចាត់ចែងរក្សាការពារលើអចលនវត្ថុ

# ជំពូកទី១
# សញ្ញាណទូទៅនៃការចាត់ចែងរក្សាការពារលើអចលនវត្ថុ

ការចាត់ចែងរក្សាការពារ គឺជានីតិវិធីមួយបង្កើតឡើងដើម្បីការពារផលប្រយោជន៍របស់ម្ចាស់បំណុលមុនពេលបណ្ដឹងអង្គសេចក្ដីត្រូវបានសម្រេចជាស្ថាពរ ឬមានអានុភាពអនុវត្តដីកាសម្រេច។ ជាការពិតណាស់វាអាចជួយដល់ម្ចាស់បំណុល ប្រសិនបើនៅក្នុងអំឡុងពេលនីតិវិធីបណ្ដឹងអង្គសេចក្ដី កូនបំណុលទុច្ចរិតជាអាទិ៍ ដោយធ្វើការផ្ទេរទ្រព្យសម្បត្តិនៃការទទួលខុសត្រូវរបស់ខ្លួនទៅតតិយជន ជាហេតុនាំឱ្យម្ចាស់បំណុលពិបាក ឬមិនអាចអនុវត្តសិទ្ធិរបស់ខ្លួនបាននៅពេលឈ្នះក្ដីជាដើម។

## ផ្នែកទី១៖ គោលគំនិតនៃការចាត់ចែងរក្សាការពារលើអចលនវត្ថុ

ការចាត់ចែងរក្សាការពារ ជានីតិវិធីមួយដែលមានគោលបំណងការពារ និងថែរក្សាស្ថានភាពបច្ចុប្បន្ន ដោយប្រើអំណាចរបស់រដ្ឋ ដើម្បីការពារសិទ្ធិរបស់បុគ្គលណាម្នាក់ នៅពេលដែលមានការបារម្ភថា នឹងមិនអាចធ្វើបាន ឬនិង មានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត ឬនៅពេលដែលមានការបារម្ភថា នឹងមានការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដល់ឋានៈរបស់ភាគីណាមួយ ដោយសារមានវិវាទអំពីទំនាក់ទំនងនៃសិទ្ធិ ឬអាចនិយាយបានថា ការចាត់ចែងរក្សាការពារវាជានីតិវិធីមួយ ដែលមានលក្ខណៈបណ្ដោះអាសន្នដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ម្ចាស់បំណុល នៅពេលដែលមានការបារម្ភថាការអនុវត្តដោយបង្ខំ ឬការសម្រេចសិទ្ធិរបស់ម្ចាស់បំណុលមិនអាចធ្វើបានដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ន នៃទ្រព្យសម្បត្តិរបស់កូនបំណុល ឬប្រសិនបើមានការបារម្ភថា នឹងមានការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដល់ឋានៈរបស់ភាគីណាមួយដោយសារមានវិវាទអំពីទំនាក់ទំនងនៃសិទ្ធិ[1]។

ការអនុវត្តដោយបង្ខំ ត្រូវបានធ្វើឡើងដោយផ្អែកលើលិខិតបញ្ជាក់កាតព្វកិច្ច ដូចជាសាលក្រមស្ថាពរជាដើម ហេតុនេះហើយដើម្បីឱ្យបានសាលក្រមនេះ ត្រូវដាក់ពាក្យបណ្ដឹងរដ្ឋប្បវេណី ថែមទាំងត្រូវការពេលវេលាច្រើន។ ក៏ប៉ុន្តែ មុនពេលទទួលបានសាលក្រមនេះ កូនបំណុលនៃការអនុវត្តអាច លក់ ឬផ្ទេរទ្រព្យសម្បត្តិរបស់ខ្លួនដែលជាហេតុមិនអាច ឬធ្វើឱ្យមានការពិបាក និងធ្វើការអនុវត្តដោយបង្ខំនៅពេលក្រោយបាន ឬមួយក៏ភាគីណាម្ខាងអាចទទួលនូវការខូចខាតធ្ងន់ធ្ងរ ឬអាចទទួលនូវគ្រោះថ្នាក់ធ្ងន់ធ្ងរដល់ឋានៈរបស់ខ្លួន ដោយសារវិវាទពាក់ព័ន្ធនិងទំនាក់ទំនងនៃសិទ្ធិរវាងភាគីទាំងសងខាង[2]។ ក្នុងករណីនេះ បុគ្គលដែលចង់ការពារសិទ្ធិរបស់ខ្លួននោះអាច

[1] មាត្រា ៥៣០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[2] ទំព័រទី ៥២៥ ចំណុច ២ នៃសេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី ១៧ មករា ២០០៧

ទាមទារឱ្យចាត់ចែងរក្សាការពារសិទ្ធិ ឬទំនាក់ទំនងគតិយុត្តរបស់ខ្លួនបាន។ ជាងនេះទៅទៀតមិនត្រឹមតែជាច្បាប់ទម្រង់ប៉ុណ្ណោះទេ សូម្បីតែច្បាប់សារធាតុ ក៏បានជួយធ្វើការអន្តរាគមន៍ផងដែរ ក្នុងការការពារសិទ្ធិ និងផលប្រយោជន៍របស់ម្ចាស់បំណុល ក្នុងករណីដែលកូនបំណុលចង់យកទ្រព្យសម្បត្តិដែលមាននោះ គេចវេសពីការអនុវត្តដោយបង្ខំដោយការឃុបឃិតគ្នាជាមួយ នឹងតតិយជន ក៏ត្រូវបានចាត់ទុកជាមោឃៈដែរ។ ផ្ទុយទៅវិញបើតតិយជននោះ ជាជនសុចរិតម្ចាស់បំណុលក៏មិនអាចអះអាងចំពោះតតិយជននោះបានដែរ[3]។ ត្រង់ចំណុចនេះហើយដែលធ្វើឱ្យម្ចាស់បំណុលជ្រើសរើសយកវិធានចាត់ចែងរក្សាការពារ ដែលជាមធ្យោបាយដ៏ល្អមួយដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ខ្លួន។

### ១.១ និយមន័យនៃការចាត់ចែងរក្សាការពារ

ការចាត់ចែងរក្សាការពារ គឺជានីតិវិធីដែលមានគោលបំណងការពារ និងថែរក្សាស្ថានភាពបច្ចុប្បន្នដោយប្រើអំណាចរបស់រដ្ឋ ដើម្បីការពារសិទ្ធិរបស់ម្ចាស់បំណុល នៅមានពេលការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ដោយសារតែមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ន នៃទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត ឬនៅពេលដែលមានការបារម្ភថា នឹងមានការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ ដល់ឋានៈរបស់ភាគីណាមួយ ដោយសារមានវិវាទអំពីទំនាក់ទំនងនៃសិទ្ធិ[4]។

### ១.២ ទស្សនៈរួមនៃការចាត់ចែងរក្សាការពារ

ទស្សនៈរួមនៃការចាត់ចែងរក្សាការពារមានភាពធំទូលាយណាស់ ព្រោះការអនុវត្តការចាត់ចែងរក្សាការពារធ្វើឡើងទៅបានលុះត្រាតែមានដីកាសម្រេចដែលចេញដោយតុលាការមានសមត្ថកិច្ច។ ចំពោះការអនុវត្តបានគ្របដណ្តប់លើការរឹបអូសជាបណ្តោះអាសន្ន និងការចាត់ចែងជាបណ្តោះអាសន្ន និងបានរួមបញ្ចូលផងដែរចំពោះបណ្តឹងទាក់ទងនឹងឋានៈបុគ្គល និងនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។ វិសាលភាពនៃការអនុវត្ត មានលក្ខណៈធំទូលាយ ផ្អែកលើគោលការណ៍ការពារនូវភាពស្របច្បាប់របស់ដើមបណ្តឹង។

## ផ្នែកទី២៖ ភាពចាំបាច់ និងលក្ខណៈពិសេសនៃការចាត់ចែងរក្សាការពារ

### ២.១ ភាពចាំបាច់នៃការចាត់ចែងរក្សាការពារ

ការចេញដីកាសម្រេចរក្សាការពារ ជាលក្ខខណ្ឌមួយដែលតុលាការត្រូវពិចារណា មិនត្រឹមតែផ្អែកទៅលើអត្ថិភាពនៃសិទ្ធិដែលត្រូវបានរក្សាការពារប៉ុណ្ណោះទេ តែត្រូវផ្អែកទៅលើភាពចំបាច់នៃរក្សាការពារផងដែរ[5]។ ភាពចាំបាច់ដែលមានអត្ថិភាព គឺការអនុវត្តដោយបង្ខំនាពេលអនាគត ទើបត្រូវបានចាត់ទុកថាមានភាពចាំបាច់

[3] មាត្រា ៣៥៣ នៃក្រមនីតិរដ្ឋប្បវេណី ៨ ធ្នូ ២០០៧

[4] មាត្រា ៥៣០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[5] ទំព័រទី ១៩៧ នៃសេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី

ក្នុងករណីដែលស្ថានភាពទ្រព្យសម្បត្តិរបស់កូនបំណុលទំនងជានឹងធ្លាក់តម្លៃ ជាអបរិមាណ ឬ មានការប្រែប្រួលស្ថានភាពទំនាក់ទំនងគតិយុត្ត ដោយសារការចាយវាយខ្ជះខ្ជាយ ការលក់ក្នុងតម្លៃថោក ការខូចខាត ការបំបាត់ជាអាទិ៍។ មិនត្រឹមតែប៉ុណ្ណោះការចាត់ចែងរក្សាការពារ ក៏ត្រូវចាត់ទុកថាមានភាពចាំបាច់ ក្នុងករណីដែលកូនបំណុលបានគេចខ្លួន ឬបានប្តូរលំនៅដ្ឋានច្រើនលើកច្រើនសារ ហើយបើការណ៍នោះ ត្រូវបានយល់ឃើញថាជាឧបសគ្គចំពោះការអនុវត្តដោយបង្ខំនាពេលអនាគត។ ហើយភាពចាំបាច់នៃការចាត់ចែងរក្សាការពារ គឺអាស្រ័យទៅតាមប្រភេទនៃដីកាសម្រេចរក្សាការពារដូចជា៖ ភាពចាំបាច់នៃការរឹបអូសជាបណ្តោះអាសន្ន អាចចេញបានចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ ក្នុងករណីបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអុវត្តដោយបង្ខំ[6]។ ភាពចាំបាច់នៃការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ត្រូវបានទទួលស្គាល់ក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ[7]។ ភាពចាំបាច់នៃការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន ត្រូវបានទទួលស្គាល់ ក្នុងករណីដែលមានភាពចាំបាច់ដើម្បីចៀសវាងការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់ដែលនឹងកើតឡើងដល់ម្ចាស់បំណុល ចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ[8]។

## ២.២ លក្ខណៈពិសេសនៃការចាត់ចែងរក្សាការពារ

ការចាត់ចែងរក្សាការពារមានលក្ខណៈពិសេសជាងនីតិវិធីបណ្តឹងអង្គសេចក្តី ឬនីតិវិធីអនុវត្តដោយបង្ខំ។ បើប្រៀបធៀបទៅនឹងបណ្តឹងអង្គសេចក្តីនោះ គឺត្រូវប្រើពេលវេលាយូរណាស់ បើគិតចាប់តាំងពីដាក់ពាក្យបណ្តឹងរហូតដល់ពេលចេញសាលក្រម ឬ សាលដីកាចូលជាស្ថាពរ។ ម្យ៉ាងក្នុងអំឡុងពេលដំណើរការនីតិវិធីបណ្តឹងប្រសិនបើជាកូនបំណុលផ្ទេរទ្រព្យសម្បត្តិរបស់ខ្លួនទៅឱ្យតតិយជនតាមទំនើងចិត្តនោះ ទោះជាម្ចាស់បំណុលបានឈ្នះក្តីក៏មិនអាចអនុវត្តដោយបង្ខំបានដែរ។ ដើម្បីបង្ការកុំឱ្យមានបញ្ហាកើតឡើង ច្បាប់បង្កើតឱ្យមានយន្តការសង្គ្រោះជាបណ្តោះអាសន្ន ទម្រាំសិទ្ធិត្រូវបានសម្រេចជាស្ថាពរដោយសាលក្រម ឬ សាលដីកា នោះគឺជានីតិវិធីនៃការចាត់ចែងរក្សាការពារ។ ជាងនេះទៅទៀតនីតិវិធីការចាត់ចែងរក្សាការពារមានលក្ខណៈពិសេសបួនយ៉ាងដូចខាងក្រោម៖

[6] មាត្រា ៥៤៥ ក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[7] មាត្រា ៥៤៨ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[8] មាត្រា ៥៤៨ កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

- លក្ខណៈបណ្ដោះអាសន្ន គឺជានីតិវិធីមួយដែលធ្វើឡើងដោយបណ្ដោះអាសន្នមានន័យថាដីកាសម្រេចរក្សាការពារ ពុំមានឥទ្ធិពលទៅលើសេចក្ដីសម្រេចដោយសាលក្រម ឬ សាលដីកា ក្នុងបណ្ដឹងអង្គសេចក្ដីឡើយ។ ទោះបីដីកាសម្រេចរក្សាការពារបានចេញដោយតុលាការក៏ដោយ ក៏សិទ្ធិលើបំណុល ឬ សិទ្ធិទាមទារផ្សេងៗទៀត នៃបណ្ដឹងអង្គសេចក្ដីមិនត្រូវបានបញ្ជាក់ថាមានអត្ថិភាព ឬ នត្ថិភាពឡើយ។

- លក្ខណៈបន្ទាន់បង្ខំ គឺជាការប្រញាប់ដើម្បីការពារផលប្រយោជន៍ស្របច្បាប់ ឬ បង្ការកុំឱ្យមានការខូចខាតធ្ងន់ធ្ងរកើតមានឡើងចំពោះម្ចាស់បំណុល តាមរយៈការទទួលស្គាល់សិទ្ធិរបស់ម្ចាស់បំណុលនៅពេលមានការស្នើសុំ ដោយមិនចាំបាច់ធ្វើការសាកសួរកូនបំណុលនោះទេ តុលាការ គឺគ្រាន់តែពិនិត្យសេចក្ដីបញ្ជាក់ដំបូងជាការគ្រប់គ្រាន់ហើយ។ ប៉ុន្តែជាគោលការណ៍ តុលាការចេញដីកាសម្រេចរក្សាការពារតាមការស្នើសុំរបស់ម្ចាស់បំណុល ប្រសិនបើតុលាការទទួលស្គាល់ថា ម្ចាស់បំណុលមានសិទ្ធិដែលត្រូវរក្សាការពារ និងមានភាពចាំបាច់ តុលាការមិនបាច់សាកសួរ កូនបំណុលឡើយ ប៉ុន្តែបើការរក្សាការពារនោះពាក់ព័ន្ធនឹងឋានៈបុគ្គល តុលាការអាចចេញដីកាសម្រេចរក្សាការពារបានលុះត្រាតែ ធ្វើការសាកសួរកូនបំណុល ឬកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ លើកលែងតែការសាកសួរ ឬការទាញហេតុផលផ្ទាល់មាត់នោះបណ្ដាលឱ្យការចេញដីកាសម្រេចរក្សាការពារប្រែជាគ្មានន័យ។ ជាងនេះទៅទៀតម្ចាស់បំណុលនូវពេលដែលទទួលបានដីកាសម្រេចរក្សាការពារ ត្រូវដាក់ពាក្យសុំអនុវត្តដីកាសម្រេចរក្សាការពារនោះ ក្នុងអំឡុងពេលពីរសប្ដាហ៍ ប្រសិនមិនបានអនុវត្តនោះទេ នាំឱ្យដីកាសម្រេចរក្សាការពារនោះមិនអាចអនុវត្តបានឡើយ។

- លក្ខណៈបន្ទាន់បន្សំ គឺជាការប្រញាប់ដើម្បីការពារផលប្រយោជន៍ស្របច្បាប់ ឬ បង្ការកុំឱ្យមានការខូចខាតដែលរំពឹងថានឹងកើតឡើងនៅពេលឆាប់ៗជាក់ជាមិនខាន។ វិធានរក្សាការពារ មានលក្ខណៈរណបឱ្យបណ្ដឹងអង្គសេចក្ដី មានន័យថាតុលាការតម្រូវឱ្យម្ចាស់បំណុលដាក់បណ្ដឹងអង្គសេចក្ដីក្នុងអំឡុងពេលសមរម្យ ប្រសិនបើមានការស្នើសុំរបស់កូនបំណុល។ ក្នុងករណីនេះ ប្រសិនបើម្ចាស់បំណុលមិនបានដាក់បណ្ដឹងអង្គសេចក្ដីមកតុលាការក្នុងអំឡុងពេលកំណត់ តុលាការត្រូវលុបចោលដីកាសម្រេចរក្សាការពារនោះ តាមការស្នើសុំរបស់កូនបំណុល។ ប្រសិនបើគ្មានសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលនឹងត្រូវបានរក្សាការពារតុលាការនឹងមិនចេញដីកាសម្រេចរក្សាការពារតាមការស្នើសុំរបស់ម្ចាស់បំណុលនោះទេ ក្នុងករណីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ ត្រូវបានរលត់នាពេលក្រោយ ដោយហេតុលត់កាតព្វកិច្ចរបស់កូនបំណុល ឬម្ចាស់បំណុលចាញ់បណ្ដឹងអង្គសេចក្ដី ហើយសេចក្ដីសម្រេចនៃបណ្ដឹងអង្គសេចក្ដីបានចូលជាស្ថាពរ ជាមូលហេតុតុលាការអាចលុបចោលដីកាសម្រេចរក្សាការពារនោះវិញបានតាមពាក្យសុំរបស់កូនបំណុល។

- លក្ខណៈសម្ងាត់ គឺជាវិធានរក្សាការពារដែលត្រូវបានបង្កើតឡើងក្នុងគោលបំណងការពារនៅផលប្រយោជន៍ស្របច្បាប់របស់ម្ចាស់បំណុល ដោយមិនឱ្យកូនបំណុលបានដឹងខ្លួនជាមុន តាមរយៈការអនុវត្តដីកាសម្រេចរក្សាការពាររួចរាល់ទើបជូនដំណឹងទៅកូនបំណុលជាក្រោយ ពីព្រោះប្រសិនបើកូនបំណុលបានដឹងជាមុនអំពីការចាត់ចែងរក្សាការពារនោះ អាចនឹងមិនទទួលបានជោគជ័យក្នុងការអនុវត្តដីកាសម្រេចរក្សាការពារ ហេតុនេះដើម្បីបញ្ចៀសនូវហានិភ័យបែបនេះ តុលាការត្រូវអនុវត្តនីតិវិធីរក្សាការពារដោយសម្ងាត់។ ក្នុងករណីនេះ ប្រសិនបើកូនបំណុលយល់ថាប៉ះពាល់ផលប្រយោជន៍ស្របច្បាប់របស់ខ្លួន អាចធ្វើការតវ៉ាបាន ហើយប្រសិនបើតុលាការទទួលស្គាល់អំពីការតវ៉ារបស់កូនបំណុលនោះតុលាការនឹងលុបចោល ឬ ផ្លាស់ប្តូរសេចក្តីសម្រេចដើម។ ភាពសម្ងាត់នេះគឺដើម្បីការពារផលប្រយោជន៍ឱ្យអ្នកដាក់ពាក្យសុំ ទោះបីជានីតិវិធីនេះបានធ្វើឱ្យបាត់បង់នូវគោលការណ៍ចំពោះមុខក៏ដោយ ស្របតាមមាត្រា ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីក៏ដោយ។

# ជំពូកទី២
# ដំណើរការនីតិវិធីនៃ
# ការចាត់ចែងរក្សាការពារលើអចលនវត្ថុ

# ជំពូកទី២

# ដំណើរការនីតិវិធីនៃការចាត់ចែងរក្សាការពារលើអចលនវត្ថុ

ដំណើរការនីតិវិធីនៃការចាត់ចែងរក្សាការពារ អាចត្រូវបានបានធ្វើឡើង មុនបណ្តឹងអង្គសេចក្តីត្រូវបានដាក់ ឬ ក្នុងពេលស្របគ្នាជាមួយបណ្តឹងអង្គសេចក្តី ឬ ក្រោយពេលបណ្តឹងអង្គសេចក្តីត្រូវបានដាក់មុនពេលដែលចេញសាលក្រម។

## ផ្នែកទី១៖ សិទ្ធិនៃការចាត់ចែងរក្សាការពារ

សិទ្ធិដែលត្រូវបានរក្សាការពារ គឺអាស្រ័យទៅតាមប្រភេទនៃដីកាសម្រេចរក្សាការពារដូចខាងក្រោម៖

### ១.១ ករណីការរឹបអូសជាបណ្តោះអាសន្ន

សិទ្ធិដែលត្រូវបានរក្សាការពារដោយការរឹបអូសជាបណ្តោះអាសន្ន ចាំបាច់ត្រូវតែជាសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាសាច់ប្រាក់[9]។

ចំពោះសិទ្ធិលើទ្រព្យសម្បត្តិ សិទ្ធិដែលទាមទារកើតចេញពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងប្រសិនបើចង់សម្រេចដោយឱ្យសង ឬបង់ជាប្រាក់ ក៏អាចសុំឱ្យចាត់ចែងរក្សាការពារ តាមរយៈការរឹបអូសជាបណ្តោះអាសន្នបានដែរ។ ចំពោះសិទ្ធិទាមទារដែលត្រូវបានរក្សាការពារ អាចជាសិទ្ធិដែលភ្ជាប់នូវលក្ខខណ្ឌ ឬ អាចជាពេលកំណត់ច្បាស់លាស់។ ប៉ុន្តែចំពោះសិទ្ធិទាមទារដែលភ្ជាប់នូវលក្ខខណ្ឌបង្អង់ចាំបាច់ត្រូវមានអត្ថិភាពជាមូលដ្ឋាននៃសិទ្ធិ។

ឧទាហរណ៍៖ សិទ្ធិទាមទារឱ្យសងសំណងនៃការខូចខាត ឬ សិទ្ធិទាមទារឱ្យបង់ថ្លៃជាដើម។

### ១.២ ករណីការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

សិទ្ធិដែលត្រូវបានរក្សាការពារដោយការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ គឺជាសិទ្ធិលើបំណុលដែលមិនមែនទាមទារជាប្រាក់ គឺមានគោលបំណងដើម្បីរក្សាស្ថានភាពបច្ចុប្បន្ននៃវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះ[10]។ ហើយសិទ្ធិដែលត្រូវបានការពារនោះរួមមាន៖ សិទ្ធិទាមទារឱ្យប្រគល់វត្ថុ សិទ្ធិទាមទារឱ្យបណ្តេញបុគ្គលចេញពីដី ឬអាគារ សិទ្ធិទាមទារឱ្យដកចេញនូវការសាងសង់ សិទ្ធិទាមទារឱ្យចុះបញ្ជីអំពីសិទ្ធិដែលមានលើវត្ថុ សិទ្ធិទាមទារមិនឱ្យធ្វើសកម្មភាពពាក់ព័ន្ធ និងការប្រើប្រាស់វត្ថុ ជាអាទិ៍។

ឧទាហរណ៍៖ ការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់លើអចលនវត្ថុ។

[9] មាត្រា ៥៣១ ចំណុច ក និង មាត្រា៥៤៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[10] មាត្រា ៥៣១ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

ឧទាហរណ៍៖ គំរូនៃការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ អាចជាការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់អចលនវត្ថុ ដើម្បីរក្សាការពារសិទ្ធិទាមទារឱ្យបណ្ដេញចេញពីអចលនវត្ថុនោះ ការចាត់ចែងជាបណ្ដោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ ដើម្បីរក្សាការពារសិទ្ធិទាមទារឱ្យចុះបញ្ជីអំពីសិទ្ធិលើអចលនវត្ថុ ជាអាទិ៍។ សិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ដែលមានគោលបំណងជាការចាត់ចែង ដូចជា អនុប្បទាន[11] និងការប្រមូល ត្រូវចាត់ទុកដូចជាវត្ថុ ហើយដោយហេតុនេះ អាចក្លាយជាកម្មវត្ថុនៃការចាត់ចែងជាបណ្ដោះអាសន្នប្រភេទនេះបាន។

### ១.៣ ករណីការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន

សិទ្ធិដែលត្រូវបានរក្សាការពារ ដោយការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន វាអាចជាសិទ្ធិលើទ្រព្យសម្បត្តិ ឬសិទ្ធិដែលទាក់ទងនឹងឋានៈបុគ្គល[12]។

ឧទាហរណ៍៖ ទំនាក់ទំនងសិទ្ធិផ្ដាច់មុខដូចជា កម្មសិទ្ធិ សិទ្ធិកាន់កាប់ សេរភាព សិទ្ធិពាណិជ្ជនាម និងសិទ្ធិលើការប្រកាសនីយកម្មបត្រតក្កកម្ម ទំនាក់ទំនងបន្តរវាងសិទ្ធិប្រត្យក្សដូចជា ទំនាក់ទំនងរវាងដីដែលនៅជាប់គ្នា កម្មសិទ្ធិអវិភាគ ទំនាក់ទំនងគតិយុត្តបន្តដូចជា កិច្ចសន្យាក្រុមហ៊ុន ភតិសន្យាការងារ ការផ្គត់ផ្គង់អាហារកាតព្វកិច្ច និងទំនាក់ទំនងឋានៈបុគ្គលដូចជា ទំនាក់ទំនងអាពាហ៍ពិពាហ៍ និងទំនាក់ទំនងរវាងឪពុកម្ដាយ និងកូន។

ឧទាហរណ៍៖ ករណីដែលបុគ្គលណាម្នាក់ពិបាក នឹងរស់នៅដោយគ្មានការផ្គត់ផ្គង់ (អាហារកាតព្វកិច្ច) ឬការបើប្រាក់បៀវត្ស ករណីដែលបុគ្គលណាម្នាក់ពិបាក និងទទួលបានការព្យាបាល ឬមិនងាយនឹងជាពីជំងឺប្រសិនបើគ្មានការទទួលការសងប្រាក់ធានារ៉ាប់រង ជាអាទ៍។

## ផ្នែកទី២៖ ការដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ

នីតិវិធីរក្សាការពារ បើម្ចាស់បំណុលចង់ដាក់រក្សាការពារទៅលើទ្រព្យសម្បត្តិរបស់កូនបំណុលនោះម្ចាស់បំណុលត្រូវដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ទៅតុលាការដែលមានសមត្ថកិច្ច[13]។ ពាក្យសុំនោះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ[14]។ គោលបំណងនៃការកំណត់បែបនេះ គឺដើម្បីធានានូវភាពច្បាស់លាស់[15]។ ហើយនៅក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ត្រូវសរសេរទៅតាមលក្ខខណ្ឌដែលច្បាប់បានកំណត់។

[11] អនុប្បទានការផ្ទេរសិទ្ធិ ឬទ្រព្យសម្បត្តិរបស់បុគ្គលណាម្នាក់ដែលជាអនុប្បទាយី ទៅឱ្យបុគ្គលម្នាក់ទៀតដែលជាអនុប្បទានិក។

[12] មាត្រា ៥៣១ ចំណុច គ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[13] មាត្រា ៣១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[14] មាត្រា ៥៣៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[15] ទំព័រទី ១៩៩ នៃសេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី

## ២.១ ការសរសេរពាក្យសុំ

ការសរសេរពាក្យសុំត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវគោរពទៅតាមចំណុចសំខាន់ៗដែលត្រូវសរសេរនៅក្នុងពាក្យសុំដូចខាងក្រោម[16]៖

### ២.១.១ ចំណុចត្រូវសរសេរក្នុងពាក្យសុំ

**ក.** ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់[17]៖ ចំណុចនេះត្រូវមានការបញ្ជាក់ឱ្យបានច្បាស់នូវ អត្តសញ្ញាណរបស់គូភាគី ប្រសិនបើគូភាគីមានអ្នកតំណាងរបស់ខ្លួន នោះត្រូវបញ្ជាក់បន្ថែមនូវអត្តសញ្ញាណរបស់អ្នកតំណាង ទើបមានភាពងាយស្រួលក្នុងការជូនដំណឹង ឬបញ្ជូនឯកសារផ្សេងៗទៅកាន់គូភាគី។

**ខ.** ខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំទាមទារ[18]៖ ក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ អ្នកដាក់ពាក្យសុំ ឬម្ចាស់បំណុល ត្រូវដាក់ឱ្យជាក់លាក់នូវចំណុចដែលត្រូវទាមទារដូចជាការសុំឱ្យរឹបអូសជាបណ្ដោះអាសន្ន ឬការសុំឱ្យមានការចាត់ចែងជាបណ្ដោះអាសន្នជាដើម។

**គ.** សិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ[19]៖ ម្ចាស់បំណុល ឬអ្នកដាក់ពាក្យសុំរក្សាការពារគប្បីបញ្ជាក់ឱ្យបានច្បាស់លាស់ និងសរសេរនូវអង្គហេតុដែលជាមូលហេតុនៃការទាមទារ និងអង្គហេតុសំខាន់ៗក្នុងចំណោមអង្គហេតុដែលជាមូលហេតុនៃការទាមទារ។

**ឃ.** ភាពចាំបាច់នៃការរក្សាការពារ[20]៖ ត្រង់ចំណុចនេះ ម្ចាស់បំណុល ឬអ្នកដាក់ពាក្យសុំត្រូវបញ្ជាក់នូវអង្គហេតុទាំងឡាយណា ដែលបញ្ជាក់អំពីការព្រួយបារម្ភរបស់ម្ចាស់បំណុល ថាមិនអាចធ្វើបាន ឬមានការលំបាកខ្លាំងក្នុងការអនុវត្តដោយបង្ខំ។

**ង.** ឯកសារភស្តុតាង៖ ឯកសារភ្ជាប់ ឬ ភស្តុតាងជាឯកសារ និងវត្ថុតាង ជាអាទិ៍ ដែលមានភាពសំខាន់សម្រាប់បញ្ជាក់អង្គហេតុហើយការទទួលអង្គហេតុត្រូវផ្អែកសំខាន់ទៅលើភស្តុតាង។ នៅពេលដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ម្ចាស់បំណុល គប្បីសរសេរឱ្យបានច្បាស់លាស់ និងសរសេរនូវភស្តុតាងដែលបញ្ជាក់នូវសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលត្រូវបានរក្សាការពារ និងភាពចាំបាច់នៃការរក្សាការពារដើម្បីឱ្យតុលាការមានភាពងាយស្រួលក្នុងការស្វែងរកនូវទំនាក់ទំនងរវាងអង្គហេតុ និងភស្តុតាង[21]។

---

16 មាត្រា ៥៤១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

17 មាត្រា ៥៤១ កថាខណ្ឌទី១ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

18 មាត្រា ៥៤១ កថាខណ្ឌទី១ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

19 មាត្រា ៥៤១ កថាខណ្ឌទី១ ចំណុច គ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

20 មាត្រា ៥៤១ កថាខណ្ឌទី១ ចំណុច ឃ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

21 មាត្រា ១២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

**ច.** ឯកសារនៃសេចក្ដីបញ្ជាក់ដំបូង[22]៖ ត្រូវធ្វើឡើងដោយភស្តុតាងដែលអាចពិនិត្យបានភ្លាមៗ[23] ចំពោះចំណុចទី៣ និងចំណុចទី៤ ខាងលើដោយសារថា ម្ចាស់បំណុល ឬអ្នកដាក់ពាក្យសុំត្រូវធ្វើសេចក្ដីបញ្ជាក់ដំបូង ដូច្នេះ អ្នកដាក់ពាក្យសុំត្រូវភ្ជាប់ជាមួយនឹងពាក្យសុំជាលាយលក្ខណ៍អក្សរ នូវឯកសារដើម្បីធ្វើសេចក្ដីបញ្ជាក់ដំបូង។ ម្យ៉ាងទៀត អ្នកតំណាងដោយអាណត្តិ ដែលមានសិទ្ធិតំណាងនៅក្នុងបណ្ដឹងអំពីសិទ្ធិដែលត្រូវរក្សាការពារ ក៏ត្រូវមានសិទ្ធិតំណាងនៅក្នុងការដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារដែរ[24]។

## ២.២ ស្ថាប័នមានសមត្ថកិច្ចចំពោះការចាត់ចែងរក្សាការពារ

ដីកាសម្រេចរក្សាការពារត្រូវបានចេញដោយតុលាការនៅពេលមានពាក្យសុំ ការកំណត់សមត្ថកិច្ចរបស់តុលាការនេះ ពីព្រោះតែតុលាការមានច្រើន។ បើមិនបានកំណត់សមត្ថកិច្ចទេវាអាចនឹងមានការជាន់សមត្ថកិច្ច។ តុលាការដែលមានសមត្ថកិច្ចនៅក្នុងសំណុំរឿងរក្សាការពារ គឺជាសមត្ថកិច្ចផ្ដាច់មុខ។ ហេតុនេះហើយការព្រមព្រៀងរបស់ភាគីក្នុងការផ្លាស់ប្ដូរតុលាការ គឺមិនអាចធ្វើទៅរួចឡើយ។ ហើយតុលាការនោះត្រូវបានបែងចែកទៅតាមសមត្ថកិច្ចដូចខាងក្រោម៖

### ២.២.១ តុលាការដែលមានសមត្ថកិច្ចលើបណ្ដឹងអង្គសេចក្ដី

តុលាការមានសមត្ថកិច្ចលើបណ្ដឹងអង្គសេចក្ដី គឺជាតុលាការនៃតុលាការជំនុំជម្រះលើកទី១។ ប៉ុន្តែបើតុលាការនៃអង្គសេចក្ដីត្រូវបានចាត់ការក្នុងនីតិវិធីបណ្ដឹងឧទ្ធរណ៍ តុលាការដែលមានសមត្ថកិច្ចលើបណ្ដឹងអង្គសេចក្ដី គឺជាតុលាការនៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍[25]។ បើបណ្ដឹងអង្គសេចក្ដីត្រូវបានចាត់ការនៅឯតុលាការកំពូល ដោយត្រឡប់ទៅរកគោលការណ៍វិញ តុលាការដែលមានសមត្ថកិច្ចលើសំណុំរឿងរក្សាការពារជាតុលាការនៃការជំនុំជម្រះលើកទី១ ព្រោះជាគោលការណ៍តុលាការកំពូលជាតុលាការអង្គច្បាប់មិន វិនិច្ឆ័យអង្គហេតុនោះទេ ហើយសិទ្ធិជម្រះពីរដងរបស់គូភាគី នៃសំណុំរឿងរក្សាការពារមិនអាចត្រូវបានផ្ដល់ជូនឡើយ បើទទួលស្គាល់តុលាការកំពូលក្នុងនាមជាតុលាការអង្គសេចក្ដីសម្រាប់សំណុំរឿងរក្សាការពារ ហេតុនេះប្រសិនបើបណ្ដឹងអង្គសេចក្ដីបានទៅដល់តុលាការកំពូល ហើយមានភាគីណាមួយយល់ថាត្រូវធ្វើនីតិវិធីរក្សាការពារ ត្រូវដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារនោះទៅតុលាការនៃការជំនុំជម្រះលើកទី១វិញ គឺមានន័យថាតុលាការមានសមត្ថកិច្ចលើបណ្ដឹងអង្គសេចក្ដី។

[22] មាត្រា ៥៤១ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[23] មាត្រា ១៣១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[24] មាត្រា ៥៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[25] មាត្រា ៥៤០ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

### ២.២.២ តុលាការមានសមត្ថកិច្ចលើវត្ថុដែលនឹងត្រូវរឹបអូស ឬកម្មវត្ថុនៃវិវាទ

ជាគោលការណ៍អ្នកដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ក្នុងសំណុំរឿងរក្សាការពារត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការដែលមានសមត្ថកិច្ចលើបណ្តឹងអង្គសេចក្តី ឬសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុនឹងត្រូវបានរឹបអូសជាបណ្តោះអាសន្ន ឬ វត្ថុដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅ[26]។

## ២.៣ សោហ៊ុយនៃការចាត់ចែងរក្សាការពារ

### ២.៣.១ ពន្ធដាក់ពាក្យសុំ

ក្នុងករណីដែលម្ចាស់បំណុល ឬ អ្នកដាក់ពាក្យសុំ បានដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ឬ ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ឬ បណ្តឹងជំទាស់ ឬ ពាក្យសុំលុបចោលដីកាសម្រេចរក្សាការពារ ឬ ពាក្យសុំអនុវត្តរក្សាការពារ ត្រូវបង់ពន្ធចំនួន៥,០០០រៀល[27]។ ម្ចាស់បំណុល ឬ អ្នកដាក់ពាក្យសុំត្រូវបង់ពន្ធជាមុន បើពុំបានបង់ទេតុលាការ ត្រូវបង្គាប់ឱ្យម្ចាស់បំណុលបង់ពន្ធពាក្យសុំក្នុងអំឡុងពេលសមរម្យ ប្រសិនបើម្ចាស់បំណុលមិនបង់ពន្ធពាក្យសុំតាមការបង្គាប់របស់តុលាការទេ តុលាការត្រូវលើកចោលពាក្យសុំ ឬលុបចោលនីតិវិធីនៃការអនុវត្តរក្សាការពារដោយដីកាសម្រេច[28]។

### ២.៣.២ ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ

បន្ថែមលើពន្ធដាក់ពាក្យសុំដែលបានលើកឡើងខាងលើម្ចាស់បំណុល ឬអ្នកដាក់ពាក្យសុំត្រូវបង់ប្រាក់ប្រដាប់ក្តី តុលាការផ្សេងទៀតក្រៅពីពន្ធសម្រាប់នីតិវិធីដូចខាងក្រោមនេះ៖

- ចំនួនទឹកប្រាក់ចាំបាច់ដើម្បីឱ្យតុលាការធ្វើការពិនិត្យ ភស្តុតាង ការបញ្ជូនឯកសារ ឬសកម្មភាពផ្សេងទៀត តាមនីតិវិធីក្នុងបណ្តឹងរដ្ឋប្បវេណី[29]។
- ចំនួនទឹកប្រាក់ស្មើនឹងសោហ៊ុយធ្វើដំណើរនិងសោហ៊ុយស្នាក់នៅដែលចាំបាច់សម្រាប់ចៅក្រម និងក្រឡាបញ្ជី ក្នុងករណីដែលត្រូវទៅនៅក្រៅតុលាការ[30]។
- ប្រាក់ប្រដាប់ក្តីសម្រាប់សមក្មភាពដែលធ្វើឡើងដោយពាក្យសុំ គឺអ្នកដាក់ពាក្យសុំ រីឯចំពោះប្រាក់ប្រដាប់ក្តី សម្រាប់សកម្មភាពដែលធ្វើឡើងដោយឆន្ទានុសិទ្ធិរបស់តុលាការ គឺអ្នកដែលតុលាការបានកំណត់ឱ្យបង់[31]។

[26] មាត្រា ៥៤០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦
[27] មាត្រា ៥៣៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦
[28] មាត្រា ៥៣៧ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦
[29] មាត្រា ៦២ កថាខណ្ឌទី១ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦
[30] មាត្រា ៦២ កថាខណ្ឌទី១ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦
[31] មាត្រា ៦២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

### ២.៣.៣ បន្ទុកនៃប្រាក់ប្រដាប់ក្ដី

ប្រាក់ប្រដាប់ក្ដីជាទូទៅជាបន្ទុករបស់ភាគីចាញ់ក្ដី[32]។ ប៉ុន្តែដោយសារតែតុលាការនៅក្នុងរឿងក្ដីរដ្ឋប្បវេណី តុលាការ គឺជាតុលាការអកម្ម ហេតុនេះហើយម្ចាស់បំណុលគួរតែស្នើសុំជាមុននៅក្នុងពាក្យបណ្ដឹងរបស់ខ្លួនដើម្បីឱ្យតុលាការវិនិច្ឆ័យ។

## ២.៤ ការវិនិច្ឆ័យ និងការត្រួតពិនិត្យលើពាក្យសុំ

### ២.៤.១ ការពិនិត្យពាក្យសុំ

ការពិនិត្យពាក្យសុំ ជាទូទៅគេតែងតែធ្វើការពិនិត្យទៅលើភាគី និងអ្នកតំណាងដែលច្បាប់បានកំណត់ និងអាសយដ្ឋានរបស់ភាគីហើយ និងអ្នកតំណាងដែលច្បាប់បានកំណត់។ ទាក់ទងនឹងការពិនិត្យពាក្យសុំនេះដែរគឺគេត្រូវពិនិត្យទៅលើសមត្ថកិច្ចផងដែរ នៅត្រង់ចំណុចនេះ គឺចង់មានន័យថា សំណុំរឿងរក្សាការពារត្រូវស្ថិតនៅក្រោមសមត្ថកិច្ចតុលាការដែលមានសមត្ថកិច្ចលើបណ្ដឹងអង្គសេចក្ដី ឬសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងនៃវត្ថុដែលត្រូវបានរឹបអូស ឬ វត្ថុដែលជាកម្មវត្ថុវិវាទស្ថិតនៅ[33]។ ចំពោះការពិនិត្យពាក្យសុំ និងការបញ្ជូនដីកាសម្រេចរក្សាការពារ ក្នុងករណីដែលពាក្យសុំសរសេរមិនបានត្រឹមត្រូវស្របតាមបញ្ញត្តិមាត្រា៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណីនោះទេ តុលាការនឹងបង្គាប់ឱ្យកែតម្រូវពាក្យសុំនោះ ដោយកំណត់ពេលក្នុងអំឡុងពេលសមរម្យដោយដីកាសម្រេចរបស់ស្ថាប័នតុលាការមានសមត្ថកិច្ច។ ដោយឡែក ប្រសិនបើម្ចាស់បំណុល មិនបានកែតម្រូវទៅតាមការកំណត់របស់តុលាការមានសមត្ថកិច្ចទេនោះ តុលាការត្រូវលើកចោលពាក្យសុំរបស់ម្ចាស់បំណុលដោយដីកាសម្រេច[34]។

### ២.៤.២ ការចេញដីកាសម្រេចចាត់ចែងរក្សាការពារ

នៅពេលដែលទទួលបានពាក្យសុំតុលាការអាចចេញដីកាសម្រេចលើកចោលពាក្យសុំ ឬដីកាសម្រេចរក្សាការពារ ក្នុងករណីដែលតុលាការចេញដីកាសម្រេចរក្សាការពារ តុលាការអាចបង្គាប់ឱ្យម្ចាស់បំណុលដាក់ប្រាតិភោគ ឬមិនដាក់ប្រាតិភោគក៏បាន។ ការបង្គាប់ឱ្យដាក់ប្រាតិភោគ អាចធ្វើនៅមុនការចេញដីកាសម្រេចរក្សាការពារ ឬដំណាលគ្នានឹងការចេញដីកាសម្រេចរក្សាការពារ[35]។

ចំពោះការប្ដូរប្រាតិភោគ និងសិទ្ធិរបស់អ្នកដែលទទួលប្រាតិភោគ និងការលុបចោលនូវប្រាតិភោគត្រូវយកបញ្ញត្តិស្ដីពីប្រាតិភោគលើបណ្ដឹងមកអនុវត្ត។ ចំពោះដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នដែលបង្គាប់ឱ្យដាក់

[32] មាត្រា ៦៤ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[33] មាត្រា ៥៤០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[34] មាត្រា ៧៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[35] មាត្រា ៥៣៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

ប្រាតិភោគ ម្ចាស់បំណុលដែលអះអាងថាដីកាសម្រេចនោះគួរចេញដោយមិនចាំបាច់ឱ្យដាក់ប្រាតិភោគអាចប្តឹងជំទាស់បាន ដីកាសម្រេចនេះអាចចាត់ទុកជាការលើកចោលពាក្យសុំមួយផ្នែក[36]។

## ផ្នែកទី៣៖ ប្រភេទនៃដីកាសម្រេចរក្សាការពារ

ប្រភេទនៃដីកាសម្រេចរក្សាការពារ វាមិនខុសគ្នាពីការចាត់ចែងរក្សាការពារនោះទេ គ្រាន់តែដីកាសម្រេចរក្សាការពារ គឺជាសេចក្តីសម្រេចរបស់តុលាការ ដែលចេញនៅពេលដែលមានពាក្យសុំឱ្យចាត់ចែងរក្សាការពារ ហើយដីកាសម្រេចរក្សាការពារនេះមានចំនួនពីរប្រភេទរួមមាន៖ ទី១ ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន និង ទី២ ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ហើយដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ននេះ ចែងចេញជាពីរទៀតគឺ ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ និងការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន[37]។

### ៣.១ លក្ខខណ្ឌនៃការចេញដីកាសម្រេចរក្សាការពារ

ការចេញដីកាសម្រេចរក្សាការពារមិនមែនតុលាការចេះតែធ្វើ ទៅតាមពាក្យសុំរបស់ម្ចាស់បំណុលនោះទេ មុននឹងចេញដីកាសម្រេចនីមួយៗ តុលាការបានគិតគូរយ៉ាងល្អិតល្អន់ទៅលើសិទ្ធិដែលត្រូវរក្សាការពារ និងភាពចាំបាច់នៃការរក្សាការពារ។

### ៣.២ ចំណុចដែលត្រូវសរសេរនៅក្នុងដីកាសម្រេចរក្សាការពារ

#### ៣.២.១ ភាពចាំបាច់ដើម្បីបញ្ជាក់រឿងក្តី

មុនពេលដែលចេញដីកាសម្រេចរក្សាការពារ តុលាការត្រូវតែសរសេរនូវចំណុចចាំបាច់មួយចំនួនដូចជា៖

- អត្តសញ្ញាណនៃភាគី អត្តសញ្ញាណនេះដែរ គឺមានទាក់ទងទៅនឹងភាគីដូចជាឈ្មោះ និងអាសយដ្ឋានរបស់ភាគី និងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។
- សញ្ញាណនៃសិទ្ធិលើបំណុលដែលបានទាមទារ ត្រង់ចំណុចនេះដែរ គឺមានទាក់ទងទៅ នឹងសិទ្ធិលើបំណុលដែលត្រូវបានរក្សាការពារ។ ហើយទាក់ទងទៅនឹងកម្មវត្ថុដែលត្រូវរក្សាការពារ ដែលវាជាចំណុចចាំបាច់សម្រាប់បញ្ជាក់រឿងក្តីផងដែរ។ ហើយម្យ៉ាងវិញទៀតដោយសារតែដីកាសម្រេចរក្សាការពារត្រូវបានចេញដោយផ្អែកលើពាក្យសុំ។

ហេតុដូច្នេះ នៅក្នុងការចេញដីកាសម្រេចរក្សាការពារ របស់ស្ថាប័នមានសមត្ថកិច្ច តុលាការមិនមែនចេញដីកាខុសសាច់រឿង ឬ ក៏អ្វីដែលគេមិនបានសុំនោះឡើយ[38]។

---

[36] មាត្រា ៥៤៦ និងមាត្រា ៥៤៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[37] ទំព័រទី ១៩៤ នៃសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី

[38] មាត្រា ៥៣១ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

### ៣.២.២ ការសរសេរបញ្ជាក់នូវកម្មវត្ថុនៃដីកាសម្រេចរក្សាការពារ

ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន តុលាការត្រូវកំណត់ឱ្យបានច្បាស់លាស់នូវ កម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្ន ហើយជាពិសេសបំផុត គឺចំពោះអចលនវត្ថុត្រូវកំណត់ឱ្យបានជាក់លាក់[39]។ ហើយភាពជាក់លាក់នៃកម្មវត្ថុចំពោះអចលវត្ថុ គឺសំដៅទៅលើព័ត៌មានសំខាន់ៗដែលរួមមាន ឯកសារដែលបានចេញដោយការិយាល័យជំនាញភូមិបាល ដែលនិយាយឱ្យចំទៅ គឺសំដៅលើប័ណ្ណកម្មសិទ្ធិលើអចលនវត្ថុរបស់កូនបំណុលតែម្តងក្នុងករណីដែលម្ចាស់បំណុលស្រាវជ្រាវរកមកបាន។

### ៣.៣ ប្រាតិភោគ

ប្រាតិភោគ គឺជាមធ្យាបាយដើម្បីធានាការសងកាតព្វកិច្ច[40]។ ដីកាសម្រេចរក្សាការពារអាចតម្រូវឱ្យដាក់ប្រាតិភោគ ឬមិនឱ្យដាក់ប្រាតិភោគបាន អាស្រ័យទៅតាមការពិចារណារបស់តុលាការ ថាតើម្ចាស់បំណុលគួរឱ្យដាក់ប្រាតិភោគ ឬមិនគួរឱ្យដាក់ប្រាតិភោគ[41]។ ចំពោះការដាក់ប្រាតិភោគ អាចជាលក្ខខណ្ឌកនៃការចេញដីកាសម្រេចរក្សាការពារ ឬអាចជាលក្ខខណ្ឌនៃការអនុវត្តរក្សាការពារ ប៉ុន្តែការដាក់ប្រាតិភោគ មិនមែនធ្វើឡើងចំពោះតែម្ចាស់បំណុលនោះទេ គឺថាការបង្គាប់ឱ្យដាក់ប្រាតិភោគនេះ តុលាការមានឆន្ទានុសិទ្ធិឱ្យកូនបំណុលដាក់ប្រាតិភោគផងដែរ ក្នុងករណីដែលតុលាការចេញដីកាសម្រេចលុបចោលរក្សាការពារ បន្ទាប់ពីតុលាការចេញដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ[42]។

ឧទារណ៍៖ ករណីដែលកម្មវត្ថុមិនអាចលក់បាន ដោយសារការរឹបអូសជាបណ្តោះអាសន្ន ហើយនៅពេលដែលលក់វិញតម្លៃរបស់វាអាចនឹងធ្លាក់តម្លៃចុះជាដើម។

### ៣.៣.១ គោលបំណងនៃប្រាតិភោគ

ជាទូទៅ តុលាការចេញដីកាសម្រេចរក្សាការពារ ដោយមិនបានសាកសួរកូនបំណុលនោះទេ និងផ្អែកលើសេចក្តីបញ្ជាក់ដំបូងរបស់ម្ចាស់បំណុលតែប៉ុណ្ណោះ នាំឱ្យមានករណីខ្លះអាចប៉ះពាល់ដល់ផលប្រយោជន៍របស់កូនបំណុលយ៉ាងខ្លាំង ហេតុនេះដើម្បីអាចការពារផលប្រយោជន៍របស់កូនបំណុល តុលាការអាចបង្គាប់ឱ្យម្ចាស់បំណុលដាក់ប្រាតិភោគបាន។ ប្រាតិភោគ ជាប្រព័ន្ធធានាសំណងនៃការខូចខាត ដើម្បីទប់ស្កាត់ការប្រើប្រាស់សិទ្ធិហួសប្រមាណរបស់ម្ចាស់បំណុល ចំពោះកូនបំណុល ក្នុងករណីម្ចាស់បំណុលចាញ់ក្តី នៅក្នុងសំណុំរឿងអង្គសេចក្តី មានន័យថា កូនបំណុលអាចទាមទារសំណងនៃការខូចខាតពីម្ចាស់បំណុល ផ្អែកលើអំពើអនីត្យានុកូល ហើយកម្មវត្ថុនៃប្រាតិភោគ នឹងក្លាយជាទ្រព្យសម្បត្តិទទួលខុសត្រូវរបស់ម្ចាស់បំណុល ហើយកូនបំណុល នឹង

[39] មាត្រា ៥៤៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[40] សន្ទានុក្រមផ្នែករដ្ឋប្បវេណី,១០១ នៃក្រមរដ្ឋប្បវេណី ៨ ធ្នូ ២០០៧

[41] មាត្រា ៥៤២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[42] មាត្រា ៥៥៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

ទទួលបានការសងជាអទិភាពចំពោះប្រាតិភោគនោះ[43]។ ប៉ុន្តែក្នុងករណីដែលតុលាការបានចេញដីកាសម្រេច មិនបានបង្គាប់ឱ្យដាក់ប្រាតិភោគ វាអាចនឹងមានការលំបាកផងដែរចំពោះកូនបំណុល ក្នុងការទាមទារសំណង នៃការខូចខាត ដែលកើតឡើងដោយសារដីកាសម្រេចរក្សាការពារ។ បើទោះបីជាកូនបំណុលអាចប្រើប្រាស់សិទ្ធិ របស់ខ្លួនតាមរយៈអំពើអនីត្យានុកូលក៏ដោយ ពីព្រោះបើម្ចាស់បំណុលមានទ្រព្យសម្បត្តិសម្រាប់រឹបអូសវាជាការ ប្រសើរ។ ផ្ទុយទៅវិញ បើម្ចាស់បំណុលមិនមានអ្វីសោះនោះ វាពិតជាមានការលំបាកចំពោះកូនបំណុល ក្នុងការ ទាមទារសំណងនៃការខូចខាត ដែលកើតឡើងដោយសារដីកាសម្រេចរក្សាការពារ។

ឧទាហរណ៍៖ A ជាជនរងគ្រោះក្នុងគ្រោះថ្នាក់ចរាចរណ៍ដែលបង្កឡើងដោយ B ហើយស្ថានភាពរបួស របស់ A ត្រូវការវះកាត់ជាបន្ទាន់ ប៉ុន្តែ A ពុំមានប្រាក់ដើម្បីធ្វើការវះកាត់ទេដែលអាចនាំឱ្យ A មានគ្រោះថ្នាក់ដល់ អាយុជីវិតក្នុងករណីនេះ A បានដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារចាត់ចែងជាបណ្តោះអាសន្នដោយ កំណត់ឋានៈជាបណ្តោះអាសន្ននៃសិទ្ធិលើបំណុលដែល A មានចំពោះ B ចំនួន ១០,០០០USD (មួយម៉ឺន) ដុល្លារអាមេរិក។ ក្នុងករណីនេះ តុលាការនឹងចេញដីកាសម្រេចរក្សាការពារដោយមិនចាំបាច់បង្គាប់ឱ្យម្ចាស់បំណុល ដាក់ប្រាតិភោគនោះទេពីព្រោះ A ពុំមានប្រាក់គ្រប់គ្រាន់ដើម្បីវះកាត់ទើបចាំបាច់ត្រូវសុំរក្សាការពារ ហេតុនេះ ប្រសិនបើតុលាការបង្គាប់ឱ្យដាក់ប្រាតិភោគច្បាស់ណាស់ A ពិតជាពុំមានលទ្ធភាពដាក់ប្រាតិភោគនោះទេ នាំឱ្យមិនអាចជួយសង្គ្រោះស្ថានភាពគ្រោះថ្នាក់របស់ A ។

**៣.៣.២ ចំនួននៃប្រាតិភោគ**

ចំនួននៃប្រាតិភោគនេះ តុលាការអាចសម្រេចឱ្យម្ចាស់បំណុលដាក់ប្រាតិភោគ ត្រូវពិចារណាជាមុនឱ្យបាន ល្អិតល្អន់លើផលប៉ះពាល់ ដែលនាំឱ្យមានការខូចខាតនៅពេលតុលាការចេញដីកាសម្រេចរក្សាការពារតាម ពាក្យសុំរបស់ម្ចាស់បំណុល ឬលុបចោលដីកាសម្រេចរក្សាការពារ តាមពាក្យសុំតវ៉ារបស់កូនបំណុល។ ហេតុនេះ តុលាការត្រូវវាយតម្លៃ និងពិចារណាអំពីការខូចខាត ដែលនឹងកើតមានដល់កូនបំណុល ឬម្ចាស់បំណុល ដោយ ផ្អែកលើមាត្រដ្ឋានមួយចំនួនដូចជា៖

- ការខូចខាតដែលអាចកើតឡើងចំពោះកូនបំណុល បច្ចុប្បន្ន និងអនាគត
- ទំហំនៃការខូចខាត បច្ចុប្បន្ន និងអនាគត
- លក្ខខណ្ឌដែលម្ចាស់បំណុល នឹងទទួលបានការរក្សាការពារ
- សេចក្តីបញ្ជាក់ដំបូងរបស់ម្ចាស់បំណុល

[43] មាត្រា ៧៤៣ នៃក្រមរដ្ឋប្បវេណី ៨ ធ្នូ ២០០៧

- ប្រភេទកម្មវត្ថុនៃការរក្សាការពារអាចជា ចលនវត្ថុ អចលនវត្ថុ សិទ្ធិលើបំណុល សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ឬនាវា ជាអាទិ៍ ។

ដូច្នេះមុននឹងចេញដីកាសម្រេចរក្សាការពារ គឺតុលាការត្រូវពិនិត្យនូវឯកសារនៃសេចក្តីបញ្ជាក់ដំបូង និងសាកសួរម្ចាស់បំណុល ឬពិនិត្យឯកសារ និងសាកសួរកូនបំណុល ក្នុងករណីដែលតុលាការចេញដីកាសម្រេចរក្សាការពារ តាមពាក្យសុំរបស់ម្ចាស់បំណុល ឬក្នុងករណីដែលតុលាការចេញដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារ តាមពាក្យសុំតវ៉ារបស់កូនបំណុល មានន័យថា បើការបញ្ជាក់ដំបូងមានភាពរឹងមាំ នោះចំនួននៃប្រាតិភោគក៏ទាបទៅតាមនោះដែរ ប៉ុន្តែបើសេចក្តីបញ្ជាក់ដំបូងពុំមានភាពរឹងមាំនិងច្បាស់លាស់នោះ ការដាក់ប្រាតិភោគក៏មានចំនួនច្រើនទៅតាមនោះដែរ[44]។

### ៣.៣.៣ វិធីនៃការដាក់ប្រាតិភោគ

ការដាក់ប្រាតិភោគ មិនមែនចេះតែដាក់នោះទេ គឺលុះត្រាតែតុលាការបង្គាប់ឱ្យដាក់ហើយការដាក់ប្រាតិភោគ ជាលក្ខខណ្ឌមួយដែលស្ថិតនៅក្នុងការពិចារណារបស់តុលាការដើម្បីចេញដីកាសម្រេចរក្សាការពារ។ ហេតុនេះ តុលាការអាចបង្គាប់ឱ្យម្ចាស់បំណុលដាក់ប្រាតិភោគមុនចេញដីកាសម្រេចរក្សាការពារ។ បើមិនដូច្នេះទេ ម្ចាស់បំណុលនឹងមិនអាចសម្រេចគោលបំណងរបស់ខ្លួនបានឡើយ លុះត្រាម្ចាស់បំណុលដាក់ប្រាតិភោគតាមការបង្គាប់របស់តុលាការ។ ចំនួនប្រាតិភោគ ត្រូវមានអនុភាពដោយការផ្ញើប្រាក់ ឬឧបករណ៍ដែលអាចជួញដូរបាន ដែលតុលាការទទួលស្គាល់ថាសមរម្យទៅតុលាការដែលបង្គាប់ឱ្យដាក់ប្រាតិភោគ ឬតុលាការអនុវត្តរក្សាការពារ[45]។ ចំពោះការផ្តល់នូវប្រាតិភោគ ភាគីត្រូវធ្វើតាមវិធីផ្ញើប្រាក់ ឬឧបករណ៍អាចជួញដូរបានដើម្បីឱ្យអ្នកមានសិទ្ធិលើប្រាតិភោគអាចទាមទារយកប្រាតិភោគដែលបានដាក់នោះ។

## ៣.៤ ការបញ្ជូនដីកាសម្រេចរក្សាការពារ

នៅពេលចេញដីកាសម្រេចរក្សាការពារតុលាការ ត្រូវបញ្ជូនដីកាសម្រេចរក្សាការពារទៅឱ្យគូភាគី[46]។

### ៣.៤.១ ដីកាសម្រេចបង្គាប់ឱ្យរក្សាការពារ

ការបញ្ជូនដីកាសម្រេចបង្គាប់ឱ្យរក្សាកាពារនេះ គឺមានគោលបំណងដើម្បីឱ្យភាគីបានដឹងអំពីសេចក្តីសម្រេចនៃដីការរក្សាការពារ ហើយវាក៏ជាការផ្តល់ឱកាសឱ្យកូនបំណុលធ្វើការតវ៉ា។ ដើម្បីចៀសវាងនូវការរារាំងរបស់កូនបំណុល និងការធានានូវការអនុវត្តរក្សាការពារ តុលាការអាចនឹងមិនបញ្ជូនដីកាសម្រេចនោះទៅកូនបំណុលឡើយ[47]។

---

[44] សៀវភៅមេរៀននីតិវិធីរដ្ឋប្បវេណី របស់លោកសាស្ត្រាចារ្យ អ៊ីវ ប៉ូលី

[45] មាត្រា ៥៣៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[46] មាត្រា ៥៤៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[47] មាត្រា ៥៦២ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

### ៣.៤.២ ដីកាសម្រេចលើកចោលពាក្យសុំ

ក្នុងករណីដែលតុលាការលើកចោលពាក្យសុំរបស់ម្ចាស់បំណុល ដែលបានដាក់សុំឱ្យតុលាការចេញដីកាសម្រេចរក្សាការពារ គឺមិនចាំបាច់បញ្ជូនឱ្យទៅកូនបំណុលទេដោយសារតែពុំមានការប៉ះពាល់ផលប្រយោជន៍កូនបំណុល។ ប៉ុន្តែក្នុងករណីដែលតុលាការធ្វើការសាកសួរ ឬធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ចំពោះភាគីនោះតុលាការក៏បញ្ជូនទៅកូនបំណុលផងដែរ[48]។ ហើយតុលាការត្រូវតែបញ្ជូនដីកាសម្រេចដែលលើកពាក្យសុំចោលទៅម្ចាស់បំណុល ពីព្រោះវាក៏ជាការផ្តល់ដំណឹងដល់ម្ចាស់បំណុល ដើម្បីឱ្យម្ចាស់បំណុលធ្វើបណ្តឹងជំទាស់នូវសេចក្តីសម្រេចរបស់តុលាការ។

[48] មាត្រា ២១៣ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

# ជំពូកទី៣

# ការអនុវត្តគ្រោះការពារ

# ជំពូកទី៣
# ការអនុវត្តរក្សាការពារ

ក្រោយពីតុលាការចេញដីកាសម្រេចរក្សាការពារ ម្ចាស់បំណុលត្រូវដាក់ពាក្យសុំអនុវត្តរក្សាការពារដើម្បីទទួលបានឯកសារចម្លងនៃលិខិតយថាភូតទៅអនុវត្ត តាមរយៈពេល និងទម្រង់នៃច្បាប់បានកំណត់ទើបម្ចាស់បំណុលអាចអនុវត្តដីកាសម្រេចរក្សាការពារនោះបាន។

## ផ្នែកទី១៖ ប្រភេទនៃការអនុវត្តចាត់ចែងរក្សាការពារ

ការអនុវត្តរក្សាការពារមានពីរប្រភេទ គឺការអនុវត្តរឹបអូសជាបណ្តោះអាសន្ន និងការអនុវត្តចាត់ចែងជាបណ្តោះអាសន្ន[49]។ ហើយការអនុវត្តរក្សាការពារត្រូវធ្វើឡើងដោយផ្អែកលើឯកសារចម្លងយថាភូតនៃដីកាសម្រេចរក្សាការពារ។ ប៉ុន្តែការអនុវត្តរក្សាការពារចំពោះ ឬសម្រាប់ជនក្រៅពីភាគី ដែលត្រូវបានកំណត់នៅក្នុងដីកាសម្រេចរក្សាការពារ ត្រូវធ្វើឡើង ដោយផ្អែកលើឯកសារចម្លងយថាភូតនៃដីកាសម្រេចរក្សាការពារដែល នឹងរូបមន្តអនុវត្ត[50]។

### ១.១ ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន

ការអនុវត្តរឹបអូសជាបណ្តោះអាសន្ន គឺការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះ អចលនវត្ថុ ចលនវត្ថុនានា សិទ្ធិលើបំណុល និងទ្រព្យសម្បត្តិផ្សេងៗទៀត។

#### ១.១.១ ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

អចលនវត្ថុ គឺសំដៅចំពោះដីធ្លី និងវត្ថុជាប់នៅនឹងដី ហើយមិនអាចផ្លាស់ប្តូរ ទីកន្លែងបានដូចជា អាគារ សំណង់ ដំណាំរុក្ខជាតិ ជាអាទិ៍។ មួយវិញទៀតអចលនវត្ថុ សំដៅដល់សិទ្ធិប្រត្យក្ស ឬសិទ្ធិភណ្ឌិតលើអចលនវត្ថុ និងចលនវត្ថុទាំងឡាយដែលច្បាប់កំណត់ថាជាអចលនវត្ថុ[51]។ ប៉ុន្តែ វាខុសគ្នាត្រង់ថាអចលនវត្ថុក្នុងន័យនៃការអនុវត្តរឹបអូសជាបណ្តោះអាន្ន គឺសំដៅតែទៅលើ ដី អាគារ ចំណែកនៃកម្មសិទ្ធិអវិភាគលើដី ឬអាគារនោះ សិទ្ធិជួលអចិន្ត្រៃយ៍ និងផលុបភោគ ដែលត្រូវបានចុះបញ្ជី និងចំណែកនៃសិទ្ធិទាំងនោះ ដែលជាសិទ្ធិរួម[52]។ ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ មិនដូចគ្នាទៅនឹងការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះចលនវត្ថុ ដោយការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ មិនធ្វើតាមរបៀបកាន់កាប់វត្ថុដែលជាកម្មវត្ថុរបស់អាជ្ញាសាលាឡើយ។ ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុពុំរារាំងដល់កូនបំណុលក្នុង

[49] ទំព័រទី ១៩៤ នៃសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី
[50] មាត្រា ៥៦២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦
[51] មាត្រា ១២០ កថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ៨ ធ្នូ ២០០៧
[52] មាត្រា ៤១៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

ការប្រើប្រាស់ និងអាស្រ័យផលពីអចលនវត្ថុនោះតាមវិធីប្រើធម្មតាទេ។ ដូច្នេះកូនបំណុលមិនចាំបាច់ចាកចេញពីអចលនវត្ថុនោះភ្លាមទេ។ លើសពីនេះទៀត ក្នុងករណីកូនបំណុលបានជួលបន្តនៃអចលនវត្ថុនេះមិនប្រឆាំងនឹងអានុភាពនៃការរឹបអូសជាបណ្ដោះអាសន្នឡើយ។ ប៉ុន្តែការជួលសារជាថ្មី នៃអចលនវត្ថុទៅអ្នកដំទៃក្រោយការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន គឺកូនបំណុលមិនអាចធ្វើបានទេ បើទោះជាកូនបំណុលបានធ្វើកិច្ចសន្យារវាងកូនបំណុលជាមួយនឹងតតិយជន ពុំអាចតតាំងជាមួយម្ចាស់បំណុលបានឡើយ។

ការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ចំពោះអចលនវត្ថុត្រូវធ្វើតាមរបៀបនៃការចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុនោះ[53]។ ដើម្បីចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុក្រឡាបញ្ជីផុកផ្ដាក់ទៅស្ថាប័នមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន។ ការចុះបញ្ជីនៃការរឹបអូសជាបណ្ដោះអាសន្ន ការិយាល័យចុះបញ្ជីត្រូវផ្ញើនូវឯកសារថតចម្លងដែលមានសេចក្ដីបញ្ជាក់នៃសៀវភៅចុះបញ្ជីនោះក្នុងសំណុំរឿង។

### ១.១.២ ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុ

ការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុ ត្រូវបានធ្វើឡើងតាមរបៀបកាន់កាប់ចលនវត្ថុ ដោយអាជ្ញាសាលា[54]។ ប៉ុន្តែប្រសិនបើចលនវត្ថុនោះ គឺជាប្រាក់អាជ្ញាសាលាមិនអាចដកហូតទុក ឬ ឱ្យកូនបំណុលរក្សាប្រាក់នោះទុកបានទេ។ អាជ្ញាសាលាត្រូវផ្ញើប្រាក់ដែលជាកម្មវត្ថុនៃការរឹបអូសជាបណ្ដោះអាសន្ននេះទៅតុលាការដែលខ្លួនស្ថិតនៅ[55]។ ដូចដែលបានរៀបរាប់រួចមកហើយ អាជ្ញាសាលាមិនអាចដកហូតទុកប្រាក់បានទេតែអ្វីផ្សេងក្រៅពីប្រាក់អាជ្ញាសាសាអាចធ្វើបាន ក្នុងករណីដែលមានការបារម្ភថាចលនវត្ថុដែលត្រូវបានរឹបអូសជាបណ្ដោះអាសន្ន នឹងធ្លាក់តម្លៃ ជាពិសេសបើការទុកចលនវត្ថុនេះ ត្រូវការសោហ៊ុយច្រើនហួសហេតុដើម្បីរក្សាទុកចលនវត្ថុនោះ អាជ្ញាសាលាអាចលក់ចលនវត្ថុដែលស្ថិតក្រោម ការដកហូតរបស់ខ្លួនបានតាមពាក្យសុំរបស់ម្ចាស់បំណុល ឬកូនបំណុល តាមនីតិវិធីនៃការលក់នៅក្នុងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ហើយប្រាក់ដែលបានមកនោះអាជ្ញាសាលានៅតែមិនមានសិទ្ធិក្នុងការរក្សាទុកដដែល ដែលតម្រូវឱ្យយកប្រាក់ដែលបានមកពីការលក់ចលនវត្ថុទៅផ្ញើនៅតុលាការដែលខ្លួនស្ថិតនៅ[56]។ ហើយចលនវត្ថុ គឺជាវត្ថុទាំងឡាយក្រៅពីអចលនវត្ថុ[57]។

---

[53] មាត្រា ៥៦៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[54] មាត្រា ៥៦៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[55] មាត្រា ៥៦៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[56] មាត្រា ៥៦៥ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[57] មាត្រា ១២០ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី ៨ ធ្នូ ២០០៧

### ១.១.៣ ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត

ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុល និងទ្រព្យសម្បត្តិផ្សេងទៀតត្រូវធ្វើតាមរបៀបដែលតុលាការអនុវត្តរក្សាការពារចេញដីកាសម្រេចនោះដែលហាមឃាត់មិនឱ្យកូនបំណុលទី៣ សងទៅកូនបំណុល[58]។ ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រូវធ្វើឡើងដោយមិនចាំបាច់សួរកូនបំណុលនៃការអនុវត្ត និងកូនបំណុលទី៣ ទេ[59]។ ប៉ុន្តែក្នុងករណីដែលពាក្យសុំឱ្យអនុវត្តចំពោះសិទ្ធិលើបំណុល ត្រូវបានដកវិញ ឬបើមានដីសម្រេចលុបចោលនីតិវិធីនៃការអនុវត្ត ក្រឡាបញ្ជីត្រូវជូនដំណឹងនេះទៅឱ្យកូនបំណុលទី៣ នោះ[60]។ ចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀតដែលបានចុះបញ្ជីត្រូវបានរឹបអូសក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ទៅស្ថាប័នមានសមត្ថកិច្ចក្នុងការចុះបញ្ជីបញ្ជាក់ថាសិទ្ធិលើបំណុលនោះ ត្រូវបានរឹបអូសហើយ[61]។ ជាមួយគ្នានេះដែល តុលាការអនុវត្តរក្សាការពារអាចចេញដីកាសម្រេចរឹបអូសនូវសិទ្ធិលើបំណុលទាំងអស់នៃការរឹបអូសនោះបាន។ ពេលដែលសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ត្រូវបានរឹបអូស កូនបំណុលទី៣ អាចធ្វើប្រាក់ស្មើនឹងចំនួនប្រាក់ដែលត្រូវបានរឹបអូសក្នុងចំណោមសិទ្ធិលើបំណុលនោះ ឬប្រាក់ស្មើនឹងចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុលនោះទាំងអស់ នៅតុលាការអនុវត្តបាន ហើយការអនុវត្តចំពោះសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ក្រៅពីអចលនវត្ថុ នាវា ចលនវត្ថុ និងសិទ្ធិលើបំណុលត្រូវយកមកអនុវត្តដូចគ្នាផងដែរ លើកលែងតែមានបញ្ញត្តិពិសេស។

### ១.១.៤ ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះនាវា

នាវា សំដៅទៅលើជលយានដែលមានចំណុះសរុបជាតោនស្មើនឹង និង លើសពី ២០(ម្ភៃ)តោន ទោះបីជាមិនបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជាក៏ដោយ ក៏ជលយានដែលមានចំណុះសរុបជាតោន ក្រោម២០(ម្ភៃ)តោន ហើយបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា[62]។ ការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះនាវា ត្រូវធ្វើតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន ឬ តាមរបៀបដែលបង្គាប់ឱ្យអាជ្ញាសាលាដកហូតលិខិតបញ្ជាក់សញ្ជាតិនាវា ជាអាទិ៍ ហើយផ្តល់លិខិតនោះទៅ តុលាការអនុវត្តរក្សាការពារ ឬ អាចអនុវត្តរួមគ្នាបាន[63]។ ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន។ ការអនុវត្តរឹបអូស

[58] មាត្រា ៥៦៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦
[59] មាត្រា ៤០៣ កថាខណ្ឌទី៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦
[60] មាត្រា ៤០៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦
[61] មាត្រា ៤១០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦
[62] មាត្រា ៤៥៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦
[63] មាត្រា ៥៦៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

ជាបណ្ដោះអាសន្នចំពោះនាវា វាមានភាពខុសគ្នាពីការអនុវត្តផ្សេងទៀត ត្រង់ដាក់ពាក្យសុំ ដែលពាក្យសុំឱ្យធ្វើការអនុវត្តរក្សាការពារនេះតម្រូវឱ្យអ្នកដាក់ពាក្យសុំ មិនត្រឹមតែសរសេរដូចការអនុវត្តផ្សេងទៀតទេហើយនៅសរសេរបន្ថែមអំពីទីកន្លែងដែលនាវានោះស្ថិតនៅព្រមទាំងឈ្មោះរបស់ម្ចាស់បំណុល មេបញ្ជាការ ឬបរិបាលនាវា និងទីកន្លែងដែលមេបញ្ជាការ ឬបរិបាលនាវានោះ នៅនាពេលបច្ចុប្បន្ន[64]។

## ១.២ ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន

ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន ត្រូវអនុវត្តដូចគ្នាផងដែរទៅនឹងវិធីនៃការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ឬ វិធីអនុវត្តដោយបង្ខំដែរ[65]។

ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន គឺត្រូវស្របតាមបញ្ញត្តិដូចគ្នា នឹងការអនុវត្តរឹបអូសជាបណ្ដោះអាសន្នដែរ ប៉ុន្តែលើកលែងតែមានបញ្ញត្តិពិសេសណាមួយផ្សេងពីនេះ។ ដូចដែលបានរៀបរាប់ខាងលើដែរថា ការចាត់ចែងជាបណ្ដោះអាសន្នមួយចំនួន ដែលមានគោលបំណងរបស់វាអាចសម្រេចបានដោយគ្រាន់តែបង្កើតឋានៈគតិយុត្ត ដោយដីកាសម្រេច ហើយរងចាំឱ្យកូនបំណុលអនុវត្តកាតព្វកិច្ចដោយស្ម័គ្រចិត្តជាមុនសិននោះ គឺមិនត្រូវការឱ្យមានការអនុវត្តនោះទេ។

### ១.២.១ នីតិវិធីនៃការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន

នីតិវិធីនៅក្នុងការអនុវត្តចាត់ចែងជាបណ្ដោះអាសន្នត្រូវអនុវត្តតាមវិធីដូចគ្នា ទៅនឹងវិធីរឹបអូសជាបណ្ដោះអាសន្ន ឬវិធីអនុវត្តដោយបង្ខំដែរ។ ជាការពិតណាស់ វិធីចាត់ចែងជាបណ្ដោះអាសន្ន មានច្រើនវិធីក្នុងការអនុវត្តដោយតុលាការអាចចាត់ចែងឱ្យកូនបំណុលធ្វើ ឬមិនធ្វើអំពើណាមួយជាកំណត់ ឬឱ្យកូនបំណុលផ្ដល់តាវកាលិក ឬឱ្យអ្នកថែរក្សាគ្រប់គ្រង ថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃការចាត់ចែងជាបណ្ដោះអាសន្ន ឬ ធ្វើការចាត់ចែងផ្សេងទៀតបាន តាមកម្រិតនៃភាពចាំបាច់ដើម្បីសម្រេចគោលបំណងនៃពាក្យសុំឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន[66]។ ហេតុដូច្នេះទើបពុំមានបញ្ញត្តិចែងឱ្យបានជាក់លាក់ណាមួយឡើយ អំពីនីតិវិធីនៃការអនុវត្តនេះទេ។ ការអនុវត្តនីមួយៗត្រូវតែអនុលោមទៅតាមវិធីដែលបានកំណត់ច្បាស់លាស់ នៅក្នុងសេចក្ដីសម្រេចបញ្ចប់នៃដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន។

កាអនុវត្តចាត់ចែងជាបណ្ដោះអាសន្នដែលបង្គាប់ឱ្យសងជាសាច់ប្រាក់ ត្រូវអនុលោមទៅតាមនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់[67]។ នៅក្នុងការអនុវត្តចាត់ចែងជាបណ្ដោះអាសន្នដែលបានបង្គាប់ឱ្យប្រគល់ ឬបណ្ដេញចេញពីអចលនវត្ថុ និងចលនវត្ថុ ត្រូវអនុលោមទៅតាមវិធី

[64] មាត្រា ៥៥៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[65] មាត្រា ៥៧០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ឆ្នាំ២០០៦

[66] មាត្រា ៥៤៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[67] មាត្រា ៣៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

នៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ និងចលនវត្ថុ[68]។ មួយវិញទៀត ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្នដែលបានបង្គាប់ឱ្យកូនបំណុលធ្វើ ឬ មិនធ្វើនូវសកម្មភាពអ្វីមួយ ត្រូវអនុលោមទៅតាមនីតិវិធីនៃការអនុវត្តជំនួស[69] ហើយនិងវិធានបង្ខំដោយប្រយោល[70]។ ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការចាត់ចែងវត្ថុអ្វីមួយ ត្រូវអនុលោមតាមវិធីនៃការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន។

បើសិនដីកាសម្រេចដែលហាមឃាត់មិនឱ្យកូនបំណុលផ្ទេរការកាន់កាប់វត្ថុ និងបង្គាប់ឱ្យកូនបំណុលប្រគល់វត្ថុទៅអាជ្ញាសាលា ដោយដកហូតការកាន់កាប់នោះ ហើយបង្គាប់ឱ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុនោះដើម្បីរក្សាការពារសិទ្ធិទាមទារឱ្យប្រគល់វត្ថុនោះត្រូវបានចេញ អាជ្ញាសាលាត្រូវប្រកាសជាសាធារណៈថា កូនបំណុលត្រូវបានហាមឃាត់ការផ្ទេរការកាន់កាប់ ហើយអាជ្ញាសាលា ថែរក្សាគ្រប់គ្រង វត្ថុនោះដោយបិទលិខិតប្រកាសជាសាធារណៈ តាមរបៀបដែលពុំងាយបកចេញ ឬប្រកាសជាសាធារណៈតាមរបៀបផ្សេងទៀត[71]។

### **១.២.២ អានុភាពនៃការអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន**

ការចាត់ចែងជាបណ្ដោះអាសន្នដែលបានហាមឃាត់ការចាត់ចែង៖ ប្រសិនបើមានការចាត់ចែងជាបណ្ដោះអាសន្នមានខ្លឹមសារជាការហាមឃាត់នូវការចាត់ចែងរបស់កូនបំណុលលើវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះស្រដៀងគ្នាទៅនឹងករណីនៃការរឹបអូសជាបណ្ដោះអាសន្នដែរ នៅក្នុងការចាត់ចែងរបស់កូនបំណុលដែលបានធ្វើផ្ទុយពីការហាមឃាត់នេះ គឺមិនអាចតតាំងជាមួយនឹងម្ចាស់បំណុល នៃការចាត់ចែងជាបណ្ដោះអាសន្នបានឡើយ។

ការចាត់ចែងជាបណ្ដោះអាសន្នដែលបានហាមឃាត់ការផ្ទេរការកាន់កាប់៖ ការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ផ្ទេរការកាន់កាប់ ចំពោះការចាត់ចែងជាបណ្ដោះអាសន្នណាដែលមានការប្រកាសជាសាធារណៈ។ បើមានការផ្ទេរការកាន់កាប់ដោយផ្ទុយនឹងការហាមឃាត់ ការផ្ទេរនោះមិនអាចតតាំងជាមួយនឹងម្ចាស់បំណុលនៃការចាត់ចែងជាបណ្ដោះអាសន្នបានឡើយ ហេតុនេះហើយ ម្ចាស់បំណុលអាចធ្វើការអនុវត្តដោយបង្ខំឱ្យប្រគល់វត្ថុបានដោយផ្អែកលើលិខិតអនុវត្តនៃអង្គសេចក្ដី[72]។

## **១.៣ ស្ថាប័នមានសមត្ថកិច្ចក្នុងការអនុវត្តដីកាសម្រេចរក្សាការពារ**

ជាគោលការណ៍ការអនុវត្តរក្សាការពារមានស្ថាប័នអនុវត្ត សម្រាប់អនុវត្តរក្សាការពារក្រោយពីតុលាការចេញដីកាសម្រេចរក្សាការពារ តាមពាក្យសុំជាលាយលក្ខណ៍អក្សររបស់ម្ចាស់បំណុល។ ម្ចាស់បំណុលនៃការអនុវត្តអាចដាក់ពាក្យសុំអនុវត្តរក្សាការពារទៅតុលាការ ឬ អាជ្ញាសាលាបាន។ ហើយការដាក់ពាក្យសុំឱ្យធ្វើការ

[68] មាត្រា ៥២៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[69] មាត្រា ៥២៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[70] មាត្រា ៥២៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[71] មាត្រា ៥៧១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[72] មាត្រា ៥៧១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

អនុវត្តរក្សាការពារ ត្រូវដាក់ទៅតុលាការ ឬ អាជ្ញាសាលាដែលមានសមត្ថកិច្ច។ ចំពោះស្ថាប័នដែលមានសមត្ថកិច្ចក្នុងការអនុវត្តរក្សាការពារអាស្រ័យទៅតាមកម្មវត្ថុនៃការអនុវត្តដោយសារតែការអនុវត្តរក្សាការពារ ធ្វើឡើងចំពោះកម្មវត្ថុផ្សេងៗដាច់ដោយឡែកពីគ្នា ឬអាចនិយាយបានថា វាអាស្រ័យទៅលើកម្មវត្ថុនៃការអនុវត្តរក្សាការពារ។

### ១.៣.១ ស្ថាប័នអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ

ស្ថាប័នដែលមានសមត្ថកិច្ចក្នុងការអនុវត្តរក្សាការពារចំពោះអចលនវត្ថុ តុលាការដែលមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ គឺជាតុលាការដែលបានចេញដីកាសម្រេចរក្សាការពារ[73]។

### ១.៣.២ ស្ថាប័នអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះសិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត

ស្ថាប័នអនុវត្តដីកាសម្រេចរក្សាការពារចំពោះសិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀតតុលាការដែលមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ គឺជាតុលាការដែលបានចេញដីកាសម្រេចរក្សាការពារនោះ[74]។

### ១.៣.៣ ស្ថាប័នអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះចលនវត្ថុ

ចំពោះចលនវត្ថុ វាមិនដូចគ្នាទៅនឹងអចលនវត្ថុនោះទេ ស្ថាប័នដែលត្រូវធ្វើការរឹបអូសជាបណ្ដោះអាសន្ន គឺអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែងដែលវត្ថុជាកម្មវត្ថុនោះស្ថិតនៅ[75]។

### ១.៣.៤ ស្ថាប័នអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នចំពោះនាវា

ស្ថាប័នដែលមានសមត្ថកិច្ចចំពោះការអនុវត្តរឹបអូសជាបណ្ដោះអាសន្នចំពោះនាវា គឺមានតុលាការពីរដែលមានសមត្ថកិច្ច។ ចំពោះការអនុវត្តរឹបអូសជាបណ្ដោះអាសន្នតាមរបៀប ចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន តុលាការដែលបានចេញដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ រីឯការអនុវត្តរឹបអូសជាបណ្ដោះអាសន្នតាមរបៀបដែលបង្គាប់ឱ្យដកហូតលិខិតបញ្ជាក់សញ្ជាតិនាវា គឺសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលនាវានោះស្ថិតនៅ ត្រូវមានសមត្ថកិច្ចជាតុលាការអនុវត្តរក្សាការពារ[76]។ ឧទាហរណ៍៖ នាវាមួយគ្រឿងស្ថិតនៅកំពង់ផែស្វយ័តខេត្តព្រះសីហនុ ត្រូវបានតុលាការខេត្តព្រះសីហនុសម្រេចរឹបអូសជាទ្រព្យសម្បត្តិរដ្ឋ និងរក្សាការទុកនៅកំពង់ផែស្វយ័តខេត្តព្រះសីហនុ ដោយមានការដឹកនាំដោយតំណាងរដ្ឋលេខាធិការក្រសួងយុត្តិធម៌ និងក្រុមការងារចម្រុះ បានចុះត្រួតពិនិត្យ និងវាយតម្លៃស្ថានភាពនាវានោះ[77]។

[73] មាត្រា ៥៦៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦
[74] មាត្រា ៥៦៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦
[75] មាត្រា ៥៦៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦
[76] មាត្រា ៥៦៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦
[77] គេហទំព័រក្រសួងយុត្តិធម៌ https://t.me/mojcambodianews/17010

## ផ្នែកទី២៖ ការដាក់ពាក្យសុំឱ្យអនុវត្តរក្សាការពារ

ការដាក់ពាក្យសុំឱ្យអនុវត្តដីកាសម្រេចរក្សាការពារ ត្រូវធ្វើឡើងដោយផ្អែកលើឯកសារចម្លងយថាភូតនៃដីកាសម្រេចរក្សាការពារ។ ប៉ុន្តែ ការអនុវត្តរក្សាការពារចំពោះ ឬ សម្រាប់ជនក្រៅពីភាគី ដែលត្រូវបានកំណត់នៅក្នុងដីកាសម្រេចរក្សាការពារ ត្រូវធ្វើឡើងដោយផ្អែកលើឯកសារចម្លងយថាភូតនៃដីកាសម្រេចរក្សាការពារដែលភ្ជាប់នឹងរូបមន្តអនុវត្ត[78]។

### ២.១ ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ

ពេលដាក់ពាក្យសុំឱ្យអនុវត្តរក្សាការពារម្ចាស់បំណុលត្រូវសរសេរដូចខាងក្រោម៖

- ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋាន របស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។
- សញ្ញាណនៃលិខិតអនុវត្ត
- សេចក្ដីសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់ ឬការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល។
- សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និងវិធីអនុវត្តដោយបង្ខំដែលម្ចាស់បំណុលនៃការអនុវត្តសុំ ក្នុងករណីដែលសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់។
- ខ្លឹមសារនៃសេចក្ដីសម្រេចដែលម្ចាស់បំណុលសុំ ក្នុងករណីដែលសុំអនុវត្តដោយបង្ខំតាមការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល។

ក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្តសុំឱ្យអនុវត្តដោយបង្ខំ ចំពោះផ្នែកណាមួយនៃសិទ្ធិទាមទារដែលបានសរសេរនៅក្នុងលិខិតអនុវត្តដែលបង្គាប់ឱ្យសងជាប្រាក់ ម្ចាស់បំណុលនៃការអនុវត្តត្រូវសរសេរបញ្ជាក់អំពីសេចក្ដីសុំ និងទំហំនៃសេចក្ដីសុំនោះក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំ[79]។

### ២.២ សោហ៊ុយនៃការអនុវត្តរក្សាការពារ

សោហ៊ុយនៃការអនុវត្តរក្សាការពារអ្នកដាក់ពាក្យសុំ ឬម្ចាស់បំណុល ត្រូវចំណាយទៅលើពន្ធដាក់ពាក្យសុំឱ្យធ្វើការអនុវត្តរក្សាការពារ និងសោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំទៅតាមការកំណត់របស់ស្ថាប័នដែលមានសមត្ថកិច្ច។

#### ២.២.១ ពន្ធដាក់ពាក្យសុំ

ចំពោះពន្ធដាក់ពាក្យសុំនេះម្ចាស់បំណុល ត្រូវបង់តាមការកំណត់របស់ស្ថាប័នអនុវត្តរក្សាការពារនោះ។ ប្រសិនបើកម្មវត្ថុនៃការអនុវត្តរក្សាការពារជាចលនវត្ថុម្ចាស់បំណុល ត្រូវបង់ពន្ធទៅតាមការកំណត់នៅក្នុងច្បាប់

[78] មាត្រា ៥៦២ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[79] មាត្រា ៣៤៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

ស្តីពីអាជ្ញាសាលា ហើយច្បាប់នេះនៅជាសេចក្តីព្រៀងនៅឡើយ។ ប៉ុន្តែបើក្នុងករណីការអនុវត្តរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុវិញ ម្ចាស់បំណុលមិនចាំបាច់ចំណាយសោហ៊ុយក្នុងការបង់ពន្ធសាជាថ្មីទេ ដោយសារតែនៅពេលដាក់ពាក្យសុំធ្វើការចាត់ចែងរក្សាការពារ គឺអ្នកដាក់ពាក្យសុំបានបង់សោហ៊ុយរួចហើយ គឺចំនួន ៥,០០០រៀល។

### ២.២.២ សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ

សោហ៊ុយក្រៅពីពាក្យដាក់ពាក្យសុំម្ចាស់បំណុល ដែលបានដាក់ពាក្យសុំឱ្យអនុវត្តរក្សាការពារនោះត្រូវបង់សោហ៊ុយចាំបាច់ជាមុនដែលបានកំណត់ដោយស្ថាប័នតុលាការមានសមត្ថកិច្ចក្នុងការអនុវត្តរក្សាការពារ[80]។ ហើយក្នុងន័យនេះដែរ ស្ថាប័នដែលមានសមត្ថកិច្ចក្នុង ការអនុវត្តរក្សាការពារនេះ គឺសំដៅទៅលើតុលាការ ឬ អាជ្ញាសាលា ធ្វើឡើងទៅតាមពាក្យសុំរបស់ម្ចាស់បំណុល បើពុំនោះទេតុលាការអនុវត្តរក្សាការពារអាចលើកចោលពាក្យសុំ ឬ លុបចោលនូវនីតិវិធីអនុវត្តរក្សាការពារនេះបាន។

## ២.៣ អំឡុងពេលនៃការដាក់ពាក្យសុំឱ្យអនុវត្តដីកាសម្រេចរក្សាការពារ

ការអនុវត្តដីកាសម្រេចរក្សាការពារមិនអាចអនុវត្តបានឡើយ ប្រសិនបើម្ចាស់បំណុលមិនបានដាក់ពាក្យសុំឱ្យអនុវត្តក្នុងអំឡុងពេល ០២(ពីរ) សប្តាហ៍ គិតចាប់ពីថ្ងៃដែលដីកាសម្រេចរក្សាការពារបានបញ្ជូនទៅម្ចាស់បំណុល[81]។ ចំពោះអំឡុងពេលខាងលើនេះ មិនអាចកែប្រែជាថ្មីដោយដីកាសម្រេចទទួលស្គាល់ការរក្សាការពារដែលបានចេញដោយសារមានការដាក់ពាក្យសុំតវ៉ានោះទេ ទោះបីជាអំឡុងពេលនោះផុតក៏ដោយ ក៏មិនធ្វើឱ្យដីកាសម្រេចរក្សាការពារបាត់បង់អានុភាពដែរ ប៉ុន្តែគេក៏អាចធ្វើឧបាស្រ័យចំពោះការអនុវត្តរក្សាការពារនៅក្រោយពេលផុតអំឡុងពេល ដោយការដាក់ពាក្យសុំតវ៉ាចំពោះការអនុវត្ត[82] ឬដោយបណ្តឹងជំទាស់។ ហើយបើទោះបីជានៅមុនពេលដែលដីកាសម្រេចរក្សាការពារត្រូវបានបញ្ជូនទៅដល់កូនបំណុល ក៏ដោយ ក៏ការអនុវត្តរក្សាការពារអាចធ្វើបានដែរ។

# ផ្នែកទី៣៖ ឧបាស្រ័យចំពោះដីកាសម្រេចរក្សាការពារ និងការអនុវត្តរក្សាការពារ

ឧបាស្រ័យក្នុងនីតិវិធីនៃការចាត់ចែងរក្សាការពារ គឺជាឧបាស្រ័យដែលប្តឹងតវ៉ាទៅតុលាការដែលបានចេញដីកាសម្រេចរក្សាការពារ និងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បណ្តឹងជំទាស់[83]។ ឧបាស្រ័យក៏ជាឱកាសដែលផ្តល់ឱ្យភាគីដែលមិនសុខចិត្តចំពោះការសម្រេចសេចក្តីរបស់តុលាការដោយធ្វើការតវ៉ា ឬ ប្តឹងជំទាស់បាន។

[80] មាត្រា ៥៣៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦
[81] មាត្រា ៥៦២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦
[82] មាត្រា ៣៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦
[83] មេរៀននីតិវិធីចាត់ចែងរក្សាការពារ របស់លោក វ៉ាន់ សុបញ្ញា

ចំពោះការតវ៉ាអាចធ្វើឡើងដោយកូនបំណុល ឬតតិយជនដែលមានផលប្រយោជន៍ពាក់ព័ន្ធ តតិយជនក៏មានសិទ្ធិអាចប្តឹងតវ៉ាបានចំពោះការអនុវត្តរក្សាការពារបានដែល បន្ទាប់ពីតុលាការចេញដីកាសម្រេចក្នុងករណីមួយចំនួនដែលច្បាប់អនុញ្ញាតភាគីអាចប្តឹងជំទាស់បាន។

## ៣.១ ការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

ការដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ គឺជាឱកាសដែលផ្តល់ឱ្យកូនបំណុលណាដែលពុំមានឱកាសចូលរួមក្នុងនីតិវិធីជាមុនក្នុងការសុំឱ្យមានការវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវនៃដីកាសម្រេចរក្សាការពារ ដោយសារតែដីកាសម្រេចរក្សាការពារមិនអាចប្តឹងជំទាស់ភ្លាមបានទេ។ បន្ទាប់ពីតុលាការចេញដីកាសម្រេចរក្សាការពាររួចហើយកូនបំណុលដែលមិនសុខចិត្តចំពោះដីកាសម្រេចរក្សាការពារ អាចដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ដោយដាក់ពាក្យសុំមកតុលាការដែលបានចេញដីកាសម្រេចរក្សាការពារបាន[84]។ បន្ទាប់ពីតុលាការទទួលបានពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការក៏ត្រូវគោរពនូវនីតិវិធីដែលច្បាប់បានបញ្ញត្តិទុកជាមុនផងដែរ។

ឧទាហរណ៍៖ ក្នុងករណីកូនបំណុលក្ស័យធន ឬគ្មានប្រាក់ចំណូលសម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃ ដោយសារការអនុវត្តការរឹបអូសជាបណ្តោះអាសន្ននូវប្រាក់បញ្ញើនៅធនាគាររបស់កូនបំណុល។

### ៣.១.១ ការទាញហេតុផលដោយផ្ទាល់មាត់

នីតិវិធីនៃការចេញដីកាសម្រេចចំពោះការតវ៉ាដីកាសម្រេចរក្សាការពារនេះ ក្រោយពីកូនបំណុលដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការមិនអាចចេញដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារនោះបានឡើយ បើមិនបានឆ្លងកាត់តាមកាលបរិច្ឆេទ នៃការទាញហេតុផលដោយផ្ទាល់មាត់ ឬតាមកាលបរិច្ឆេទនៃការសួរ ដែលភាគីទាំងសងខាងអាចចូលរួមបាន[85]។

### ៣.១.២ ការបញ្ចប់ការវិនិច្ឆ័យចំពោះការតវ៉ា

ដើម្បីបញ្ចប់ការវិនិច្ឆ័យអំពីការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការត្រូវសម្រេចថ្ងៃបញ្ចប់នៃការវិនិច្ឆ័យដោយកំណត់អំឡុងពេលអនុគ្រោះដ៏សមរម្យ។ ប៉ុន្តែនូវកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬការបរិច្ឆេទនៃការសួរ ដែលភាគីទាំងសងខាងអាចចូលរួមបាន តុលាការអាចប្រកាសដោយភ្លាមៗថាបញ្ចប់ការវិនិច្ឆ័យ[86]។

[84] មាត្រា ៥៥០ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[85] មាត្រា ៥៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[86] មាត្រា ៥៥៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

### ៣.១.៣ ការចេញដីកាសម្រេចចំពោះការតវ៉ាលើដីកាសម្រេចរក្សាការពារ

ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការត្រូវទទួលស្គាល់ ផ្លាស់ប្តូរ ឬ លុបចោលនូវដីកាសម្រេចរក្សាការពារ[87]។ ក្នុងករណីដែលមានការដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរបស់តុលាការអាចធ្វើការសម្រេចសេចក្តីដូចមាននៅក្នុងករណីទាំងបីខាងលើនេះបានអាស្រ័យ ទៅលើការពិចារណារបស់តុលាការក្រោយពេលចេញដីកាសម្រេចចំពោះការតវ៉ាលើដីកាសម្រេចរក្សាការពារ តុលាការត្រូវបញ្ជូនដីកាសម្រេចទៅឱ្យភាគី[88]។

## ៣.២ ការតវ៉ាចំពោះការអនុវត្តរក្សាការពារ

ការតវ៉ាចំពោះការអនុវត្តរក្សាការពារ គឺជាបណ្តឹងដែលតវ៉ាចំពោះអត្ថិភាព ឬ អត្ថន័យនៃសិទ្ធិទាមទារដែលត្រូវបានកំណត់ក្នុងលិខិតអនុវត្ត[89]។ ហើយលិខិតអនុវត្តនេះដែរ គឺសំដៅទៅលើឯកសារចំលងយថាភូតនៃដីកាសម្រេចរក្សាការពារ។

### ៣.២.១ បណ្តឹងតវ៉ារបស់តតិយជន

មិនត្រឹមតែកូនបំណុលប៉ុណ្ណោះទេដែលមានសិទ្ធិក្នុងការធ្វើការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ប៉ុន្តែតតិយជនក៏មានសិទ្ធិក្នុងការតវ៉ាផងដែរ ក្នុងករណីដែលការអនុវត្តរក្សាការពារបានប៉ះពាល់ដល់ប្រយោជន៍របស់តតិយជននោះ។ ចំពោះផលប្រយោជន៍ដែលប៉ះពាល់អាចជា កម្មសិទ្ធិ ឬ សិទ្ធិផ្សេងទៀតដែលរាំងស្ទះដល់ការធ្វើអនុប្បទាន ឬការចាត់ចែងចំពោះវត្ថុដែលជាកម្មវត្ថុនៃការអនុវត្ត អាចធ្វើការតវ៉ាបាន[90]។ ជាងនេះទៅទៀតការតវ៉ាមិនត្រឹមតែចំពោះអចលនវត្ថុប៉ុណ្ណោះទេ ថែមទាំងចលនវត្ថុទៀតផង ដែលតតិយជនអាចដាក់ពាក្យសុំតវ៉ាទៅស្ថាប័នតុលាការដែលមានសមត្ថកិច្ចក្នុងការអនុវត្តនោះវាអាចជាតុលាការ ឬ អាជ្ញាសាលា មិនថាវាមានគោលបំណងឱ្យសងជាប្រាក់ ឬ គ្មានគោលបំណងឱ្យសងជាប្រាក់។

### ៣.២.២ សមត្ថកិច្ចចំពោះដីកាសម្រេចរក្សាការពារ

ការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ គឺជាវិធីឧបាស្រ័យមួយប្រភេទ ទៅតុលាការនៃថ្នាក់ដដែល ដែលបានចេញដីកាសម្រេចនោះ។ ប៉ុន្តែក្នុងករណីដែលដីកាសម្រេចរក្សាការពារដែលបានធ្វើដោយឧទ្ធរណ៍បានធ្វើក្នុងនាមជាតុលាការអនុវត្តរក្សាការពារ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុត្រូវរឹបអូសជាបណ្តោះអាសន្ន ឬ វត្ថុដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅ[91]។

---

[87] មាត្រា ៥៥៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦
[88] មាត្រា ៥៥៤ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦
[89] មាត្រា ៣៣៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦
[90] មាត្រា ៥៦៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦
[91] មាត្រា ៥៦៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

## ៣.៣ ការសុំឱ្យលុបចោលដីកាសម្រេចរក្សាការពារ

ដីការសម្រេចរក្សាការពារ មិនត្រឹមតែត្រូវលុបចោលដោយការតវ៉ាប៉ុណ្ណោះទេ។ ដីកាសម្រេចរក្សាការពារ អាចត្រូវបានលុបចោលក្នុងករណីបីផ្សេងទៀតដូចខាងក្រោម៖

- ការលុបចោលដោយសារការមិនដាក់ពាក្យបណ្តឹងអង្គសេចក្តី តុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ត្រូវបង្គាប់ឱ្យម្ចាស់បំណុល ដាក់ពាក្យបណ្តឹងអង្គសេចក្តី ហើយឱ្យដាក់ឯកសារដែលបញ្ជាក់អំពីការដាក់ពាក្យបណ្តឹងនោះ ក្នុងអំឡុងពេលដែលទទួលស្គាល់ថាសមរម្យ តាមពាក្យសុំរបស់កូនបំណុល[92]។

- ការលុបចោលដោយសារការផ្លាស់ប្តូរស្ថានភាព បើមានការរលត់សិទ្ធិដែលត្រូវបានរក្សាការពារ ឬ ភាពចាំបាច់ក្នុងការរក្សារការពារ ឬ ការផ្លាស់ប្តូរផ្សេងទៀតនៃស្ថានភាព តុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ឬ តុលាការនៃបណ្តឹងអង្គសេចក្តី អាចលុបចោលដីកាសម្រេចរក្សាការពារ តាមពាក្យសុំរបស់កូនបំណុលបាន[93]។

- ការលុបចោលដោយសារស្ថានភាពពិសេស ប្រសិនបើមានការបារម្ភថា ការខូចខាតដែលមិនអាចសងបាននឹងកើតឡើងដោយសារ ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ឬ ស្ថានភាពពិសេសផ្សេងទៀត តុលាការដែលបានចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ឬ តុលាការនៃបណ្តឹងអង្គសេចក្តី អាចលុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ននោះបាន ដោយមានលក្ខខណ្ឌតម្រូវឱ្យដាក់ប្រាតិភោគតាមពាក្យសុំរបស់កូនបំណុល[94]។

### ៣.៣.១ ការទាញហេតុផលដោយផ្ទាល់មាត់

ដោយសារការទាញហេតុផលដោយផ្ទាល់មាត់ ឬ ការសួរនៅការបរិច្ឆេទដែលភាគីទាំងសងខាងអាចចូលរួមបាន[95] មកអនុវត្តចំពោះការសុំលុបចោលដីកាសម្រេចរក្សាការពារ។ ហេតុដូច្នេះហើយ អាចបញ្ជាក់ការលុបចោលដីកាសម្រេចរក្សាការពារ នៅក្នុងនីតិវិធីនៃការចាត់ចែងរក្សាការពារនៅពេលកូនបំណុលធ្វើការសុំឱ្យលុបចោលដីកាសម្រេចរក្សាការពារត្រូវឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ ឬ តាមកាលបរិច្ឆេទដែលភាគីអាចចូលរួមបាន។

### ៣.៣.២ ការផ្អាកលើដីកាសម្រេចរក្សាការពារ

នៅពេលដែលមានពាក្យសុំឱ្យលុបចោលដីកាសម្រេចរក្សាការពារ តុលាការអាចបង្គាប់ឱ្យផ្អាកការអនុវត្តរក្សាការពារ ឬ លុបចោលការចាត់ចែងការអនុវត្តរក្សាការពារ តាមពាក្យសុំរបស់កូនបំណុលដោយតម្រូវឱ្យដាក់

[92] មាត្រា ៥៥៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦
[93] មាត្រា ៥៥៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦
[94] មាត្រា ៥៥៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦
[95] មាត្រា ៥៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

ប្រាតិភោគបាន រហូតដល់ធ្វើការសម្រេចសេចក្តីអំពីពាក្យសុំឱ្យលុបចោលដីកាសម្រេចរក្សាការពារ ថាតើត្រូវលុបចោល ផ្លាស់ប្តូរ ឬទទួលស្គាល់នូវសេចក្តីសម្រេចជាមុនសិន[96]។

### ៣.៤ បណ្តឹងជំទាស់

បណ្តឹងជំទាស់ គឺជាវិធីឧបាស្រ័យមួយប្រភេទទៅតុលាការជាន់ខ្ពស់ ឬ អាចនិយាយម្យ៉ាងទៀតបានថា បណ្តឹងជំទាស់ គឺជាបណ្តឹងឧបាស្រ័យចំពោះដីកាសម្រេចដែលតុលាការចេញក្នុងសំណុំរឿងរក្សាការពារចំពោះករណីមួយចំនួនដែលច្បាប់បានចែងទុកជាមុន។ បណ្តឹងជំទាស់ ត្រូវដាក់ទៅតុលាការនៃការជំនុំជម្រះលើកទី១ ដោយក្រឡាបញ្ជីត្រូវបញ្ជូនពាក្យបណ្តឹងជំទាស់ទៅសាលាឧទ្ធរណ៍ ដើម្បីធ្វើការពិនិត្យបណ្តឹង និងវិនិច្ឆ័យ។

#### ៣.៤.១ មូលហេតុនៃបណ្តឹងជំទាស់

បណ្តឹងជំទាស់អាចធ្វើទៅបានអាស្រ័យដោយមូលហេតុដូចខាងក្រោម៖ ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ដីកាសម្រេចឲ្យធ្វើបដិទាន ដីកាសម្រេចអំពីពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរក្សាការពារ[97] ដីកាសម្រេចដែលលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ[98]។ ចំពោះនីតិវិធីនៃបណ្តឹងជំទាស់ វាជានីតិវិធីមួយដែលមានរយៈពេលយូរ ឬ យឺតជាងការតវ៉ាហើយការតវ៉ាគ្រាន់តែជានីតិវិធីបន្ថែមលើបណ្តឹងជំទាស់តែប៉ុណ្ណោះ។ ហើយបណ្តឹងជំទាស់ ត្រូវបានយកមកអនុវត្តដូចគ្នាចំពោះបញ្ញត្តិមួយចំនួនផងដែរទៅនឹងនីតិវិធីនៃការតវ៉ា។

#### ៣.៤.២ ការទាញហេតុផលដោយផ្ទាល់មាត់

បណ្តឹងជំទាស់ គឺជាបណ្តឹងឧបាស្រ័យរបស់ភាគីដែលធ្វើបណ្តឹងជំទាស់ទៅនឹងសេចក្តីសម្រេចរបស់តុលាការដែលសម្រេចលុបចោលដីកាសម្រេចរក្សាការពារ ឬ លើកពាក្យសុំរបស់ម្ចាស់បំណុលជាដើម ដូចដែលបានរៀបរាប់ក្នុងមូលហេតុនៃបណ្តឹងជំទាស់។ នៅពេលដែលម្ចាស់បំណុល ឬ កូនបំណុលធ្វើបណ្តឹងជំទាស់ តុលាការត្រូវកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់[99] តុលាការមិនអាចធ្វើការវិនិច្ឆ័យសេចក្តីបានទេ បើគ្មានការឆ្លងកាត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់។

#### ៣.៤.៣ ការបញ្ចប់ការវិនិច្ឆ័យចំពោះបណ្តឹងជំទាស់

ការបញ្ចប់ការវិនិច្ឆ័យចំពោះបណ្តឹងជំទាស់ វាក៏មិនខុសគ្នាពីការវិនិច្ឆ័យនៃអំពីការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ តុលាការត្រូវសម្រេចថ្ងៃបញ្ចប់ការវិនិច្ឆ័យដោយកំណត់អំឡុងពេលអនុគ្រោះដោយសមរម្យ។ ប៉ុន្តែបើ

---

[96] មាត្រា ៥៥១ កថាខណ្ឌទី១ និងកថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[97] មាត្រា ៥៦១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[98] មាត្រា ៥៤៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[99] មាត្រា ៥៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

តុលាការបានកំណត់កាលបរិច្ឆេទនៃការវិនិច្ឆ័យ តុលាការអាចប្រកាសភ្លាមៗ ថាបញ្ចប់ការវិនិច្ឆ័យ ដូចដែលបាន កំណត់ទៅតាមកាលបរិច្ឆេទ[100]។

### ៣.៤.៤ អំឡុងពេលនៃបណ្តឹងជំទាស់

ដីកាសម្រេចរក្សាការពារ ដែលបានរៀបរាប់ខាងលើ រួមមានការតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ឬ ពាក្យសុំទាមទារលុបចោលដីកាសម្រេចរក្សាការពារ ឬការធ្វើបដិទានរបស់ម្ចាស់បំណុល ជាអាទិ៍ ត្រូវបានកំណត់រយៈពេលក្នុងការប្តឹងជំទាស់ គឺមានអំឡុងពេល ០២(ពីរ)សប្តាហ៍ ចាប់ពីថ្ងៃដែលបានបញ្ជូនដីកាសម្រេចនេះទៅដល់អ្នកដែលមានសិទ្ធិក្នុងការធ្វើបណ្តឹងជំទាស់ហើយរយៈពេលដែលបានកំណត់ខាងលើមិនអាចពន្យាបានឡើយ[101]។

[100] មាត្រា ៥៥៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[101] មាត្រា ៥៦១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

# ជំពូកទី៤
# បញ្ហាប្រឈម និងដំណោះស្រាយ

# ជំពូកទី៤
# បញ្ហាប្រឈម និងដំណោះស្រាយ

នីតិវិធីចាត់ចែងរក្សាការពារមានភាពស្មុគស្មាញខ្លាំង ចាប់តាំងពីពេលដាក់ពាក្យសុំរក្សាការពារ រហូតដល់ការអនុវត្តដីកាសម្រេចរក្សាការពារ ដោយហេតុថាការចាត់ចែងរក្សាការពារមានភាពធំទូលាយ ចំពោះការអនុវត្តរក្សាការពារធ្វើឡើងទៅបាន លុះត្រាតែមានដីកាសម្រេចដែលចេញដោយតុលាការមានសមត្ថកិច្ច។ ហើយការអនុវត្តត្រូវបានគ្របដណ្តប់លើការរឹបអូសជាបណ្តោះអាសន្ន និងការចាត់ចែងជាបណ្តោះអាសន្ន និងរួមបញ្ចូលផងដែរចំពោះបណ្តឹងទាក់ទងនឹងឋានៈបុគ្គល និងនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង វិសាលភាពនៃការអនុវត្តមានលក្ខណៈធំទូលាយណាស់។ ជាងនេះទៅទៀតទោះបីជាអ្នកមានផលប្រយោជន៍ពាក់ព័ន្ធបំពេញទៅតាមលក្ខខណ្ឌដែលច្បាប់បានកំណត់ក៏ដោយ ក៏បញ្ហាតែងតែជួបប្រទះជានិច្ចជាកាលដោយខានពុំបាននេះជាហេតុធ្វើឱ្យមានការកកស្ទះ ឬ ដោយភាពចន្លោះប្រហោងនៃលិខិតបទដ្ឋានគតិយុត្ត ឬដោយហេតុកង្វះខាតមន្ត្រីអនុវត្ត ឬស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកក្នុងការអនុវត្តមិនសហការជាដើម។

## ផ្នែកទី១៖ បញ្ហាប្រឈម

### ១.១ ភាពខ្វះចន្លោះប្រហោងនៃច្បាប់

ស្របពេលសង្គមកម្ពុជាកំពុងតែអភិវឌ្ឍន៍ប្រកបដោយតម្លាភាព ទំនាក់ទំនងផលប្រយោជន៍ និងឋានៈបុគ្គល ក៏បង្កើតជាជម្លោះ និងវិវាទផ្សេងៗកើតឡើងជាលំដាប់ ហើយច្បាប់ដើរតួនាទីយ៉ាងសំខាន់សម្រាប់ដោះស្រាយនូវរាល់បញ្ហា និងវិវាទផ្សេងៗ ដែលគូភាគី ឬជនដែលជាប់ពាក់ព័ន្ធផលប្រយោជន៍អាចប្តឹងទាមទារទៅតុលាការដែលមានសមត្ថកិច្ច ប្រសិនបើខ្លួនយល់ថាបានធ្វើឱ្យខូចខាតនូវផលប្រយោជន៍ស្របច្បាប់របស់ខ្លួន។ ក្នុងឆ្នាំ២០០៦ ក្រមនីតិវិធីរដ្ឋប្បវេណី ចំនួន ៩គន្ថី ៥៨៨មាត្រា ត្រូវបានប្រកាសឱ្យប្រើដើម្បីសម្រួលក្នុងការអនុវត្ត និងដំណើរការនៃនីតិវិធីផ្នែករដ្ឋប្បវេណី ជាពិសេសត្រង់គន្ថីទី៧ ស្តីពីការចាត់ចែងរក្សាការពារ ប៉ុន្តែទោះបីជាក្រមនីតិវិធីរដ្ឋប្បវេណីត្រូវបានប្រកាសឱ្យប្រើ និងអនុវត្តនៅតាមសាលាជម្រះក្តីក៏ដោយ ក៏ពុំមានភាពពេញលេញ និងគ្រប់ជ្រុងជ្រោយឡើយ ដែលវាជាហេតុធ្វើឱ្យមានការលេចឡើងនៅបញ្ហាប្រឈមនានា និងការលំបាកក្នុងការអនុវត្តប្រកបដោយប្រសិទ្ធិភាព ព្រោះការអនុវត្តត្រង់គន្ថីទី៧ ស្តីពីការចាត់ចែងរក្សាការពារមានភាពធំទូលាយណាស់ និងជាប់ពាក់ព័ន្ធស្ថាប័នមានសមត្ថកិច្ចជាច្រើន ជាពិសេសវាក៏អាចធ្វើឱ្យខូចប្រយោជន៍ដោយប្រការណាមួយចំពោះជនដែលពាក់ព័ន្ធទៅនឹងផលប្រយោជន៍ ដើម្បីសម្រេចបាននៅគោលបំណងរបស់ខ្លួនជាដើម។

## ១.២ ការយល់ដឹងផ្នែកច្បាប់របស់ប្រជាពលរដ្ឋនៅមានកំរិត

ជាការពិតណាស់ក្រមនីតិវិធីរដ្ឋប្បវេណីទើបតែត្រូវបានប្រកាសឱ្យប្រើនាឆ្នាំ២០០៦ កន្លងមកនេះ ដែលការយល់ដឹងផ្នែកច្បាប់របស់ប្រជាពលរដ្ឋនូវមានកម្រិត ដោយហេតុថាប្រជាពលរដ្ឋគាត់មានភាពមមាញឹកប្រកបកិច្ចការងារសម្រាប់បម្រើក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ក្នុងករណីខ្លះទីកន្លែងដែលគាត់ស្នាក់នៅជាតំបន់ជនបទ ឬអាចជាតំបន់ដាច់ស្រយាលដែលមិនងាយមានការផ្សព្វផ្សាយច្បាប់ទៅដល់ ដែលនេះជាមូលហេតុនាំឱ្យមានការយល់ដឹងផ្នែកច្បាប់របស់ប្រជាពលរដ្ឋភាគច្រើននៅមានកំរិត សូម្បីតែច្បាប់ទូទៅពួកគាត់មិនសូវយល់ផងចុះទម្រាំតែនីតិវិធីនៃការចាត់ចែងរក្សាការពារលើអចលវត្ថុនោះ ពួកគាត់មិនយល់ខ្លឹមសារនៃច្បាប់ និងមិនយល់អំពីទម្រង់នៃការសេរពាក្យបណ្ដឹងផង។ ហើយវាមានការលំបាកជាខ្លាំងនៅពេលដែលពួកគាត់មានវិវាទកើតឡើងនោះ ហើយវាជាកត្តាដ៏ធំមួយធ្វើឱ្យប្រជាពលរដ្ឋមិនចូលរួមនីតិវិធីរបស់តុលាការ ដោយសារតែការមិនចេះ មិនយល់ដឹងអំពីច្បាប់នេះហើយ។

## ១.៣ កង្វះខាតអាជ្ញាសាលា និងផលវិបាកក្នុងការអនុវត្តរក្សាការពារ

ពាក្យ "អាជ្ញាសាលា" ត្រូវបានប្រើប្រាស់ក្នុងក្រមនីតិវិធីរដ្ឋប្បវេណី និងបទដ្ឋានគតិយុត្តផ្សេងទៀត ពេលខ្លះអាជ្ញាសាលា អនុវត្តតួនាទីក្នុងនាមជាស្ថាប័នឯករាជ្យ និងពេលខ្លះអាជ្ញាសាលា អនុវត្តកិច្ចការក្នុងនាមជាស្ថាប័នជំនួយរបស់តុលាការផងដែរ។ ជាការពិតណាស់អាជ្ញាសាលា ដើរតួនាទីយ៉ាងសំខាន់នៅក្នុងនីតិវិធីរក្សាការពារដែលទទួលបន្ទុកក្នុងការអនុវត្តដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នរបស់តុលាការ ដែលអាជ្ញាសាលាបានស្ថិតនៅនោះ មានន័យថាអាជ្ញាសាលាអនុវត្ត ឬបំពេញទៅបាន លុះត្រាតែតុលាការមានសមត្ថកិច្ចក្នុងការចេញដីកាសម្រេចចាត់ចែងរក្សាការពារទើបអាចអនុវត្តបាន។ ជាងនេះទៅទៀត អាជ្ញាសាលាមិនទទួលបានប្រាក់បៀវត្សពីរដ្ឋនោះឡើយ ដោយអាជ្ញាសាលាស្វែងរកប្រាក់ចំណូលបាននូវពេលដែលទទួលបន្ទុកបំពេញមុខងារក្នុងការអនុវត្តនូវដីកាសម្រេចរបស់តុលាការ ដោយគិតជាភាគរយប៉ុណ្ណោះ ដោយសារមិនទាន់មានច្បាប់ស្ដីពីលក្ខន្តិកៈអាជ្ញាសាលា ចំពោះការគិតអំពីការចំណាយក្នុងការអនុវត្ត ត្រូវធ្វើឡើងតាមក្រមនីតិវិធីរដ្ឋប្បវេណី និងប្រកាសលេខ៣០ ស្ដីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលារបស់ក្រសួងយុត្តិធម៌ ប្រការ១៣ និង១៤ ឬពន្ធដាក់ពាក្យសុំ ៥.០០០រៀល រីឯសោហ៊ុយក្រៅពីពន្ធ គឺមានកំណត់នៅក្នុងប្រការ១៤ នៃប្រកាសនេះ។ ចំពោះការកំណត់សោហ៊ុយក្រៅពន្ធត្រូវកំណត់ទៅតាមភាពជាក់ស្ដែង និងភាពចាំបាច់តែប៉ុណ្ណោះ។

ទោះបីជាមានយន្តការនៃការជ្រើសរើសសិស្សអាជ្ញាសាលាក៏ដោយ ក៏ការអនុវត្តនាពេលបច្ចុប្បន្ននេះនូវតែមានកង្វះខាតមន្ត្រីអាជ្ញាសាលា ជាក់ស្ដែងមន្ត្រីអាជ្ញាសាលាទើបតែមានមួយជំនាន់ដែលបានទទួលការបណ្ដុះបណ្ដាលដោយសាលាភូមិន្ទអាជ្ញាសាលា គឺនៅមានចំនួនខ្វះខាតច្រើនដោយនៅតាមសាលាដំបូងរាជធានី-ខេត្តនៃព្រះរាជាណាចក្រកម្ពុជានូវពុំទាន់មានមន្ត្រីអាជ្ញាសាលានៅឡើយទេ ដែលវាពិតជាមានផលប៉ះពាល់ និងមាន

ការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តនីតិវិធីនៃច្បាប់ ជាពិសេសនោះគឺការអនុវត្តដីកាសម្រេច និងទទួលបន្ទុកក្នុងអនុវត្តកិច្ចការបញ្ជូនប្រតិបត្តិការបញ្ជូនឯកសាររបស់តុលាការ[102] និងប្រតិបត្តិការបញ្ជូនសេចក្តីសម្រេចរបស់តុលាការ។

ចំពោះផលវិបាករបស់អាជ្ញាសាលាក្នុងពេលចុះអនុវត្ត ដោយនៅពេលចុះទៅអនុវត្ត គឺត្រូវមានការស្នើសុំកម្លាំងចូលរួមអនុវត្ត ហើយនីតិវិធីស្នើសុំកម្លាំងទៅស្ថាប័នមានសមត្ថកិច្ចមានភាពខុសគ្នាតាមដែនដីរដ្ឋបាលនីមួយៗ ដែលការធ្វើបែបនេះ ធ្វើឱ្យមានការចំណាយពេលវេលាច្រើន និងធ្វើឱ្យមានការយឺតយ៉ាវនីតិវិធីផងដែរ។ រីឯករណីមួយទៀតគឺ មានការប្រឆាំងនិងការអនុវត្ត ដោយភាគីចាញ់ក្តី(កូនបំណុលនៃការអនុវត្ត) តែងតែរកវិធីដែលអាចរារាំងដល់ការអនុវត្ត ហើយពេលខ្លះអាចឈានដល់ការប្រើអំពើហិង្សាទៀតផង ឬមួយក៏កម្មវត្ថុនៃការអនុវត្តត្រូវបានបាត់បង់ ឬផ្លាស់ប្តូរទីតាំង ឬបានផ្ទេរទៅបុគ្គលផ្សេង ឬក៏មិនមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន ឬការសហការពីកូនបំណុលជាដើម។

## ១.៤ ការជាន់សមត្ថកិច្ចរវាងព្រះរាជអាជ្ញា និងអាជ្ញាសាលា

ចំពោះមន្ត្រីដែលបំពេញតួនាទីជំនួសជាអាជ្ញាសាលាគ្រាន់តែអនុវត្តជាបណ្តោះអាសន្នប៉ុណ្ណោះដោយសារតែច្បាប់ស្តីពីលក្ខន្តិកៈអាជ្ញាសាលានៅជាសេចក្តីព្រាងច្បាប់នៅឡើយដែលនេះជាហេតុធ្វើឱ្យមានការរាំងស្ទះក្នុងការអនុវត្តក្រមនីតិវិធីរដ្ឋប្បវេណីយ៉ាងខ្លាំង។ ដោយឃើញបញ្ហាប្រឈមបែបនេះហើយ ក្រសួងយុត្តិធម៌ ដែលមានឯកឧត្តម **អង្គ វង្សវឌ្ឍនា** ជារដ្ឋមន្ត្រីបានចេញប្រកាសលេខ៣០ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ដោយប្រគល់ភារកិច្ចអាជ្ញាសាលា ដែលមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណីទៅឱ្យព្រះរាជអាជ្ញា-ព្រះរាជអាជ្ញារង ដែលស្ថិតនៅតាមសាលាដំបូងរាជធានី-ខេត្ត ជាបណ្តោះអាសន្ន រហូតដល់មានច្បាប់ស្តីពីអាជ្ញាសាលា[103]។

## ១.៥ ការធ្វេសប្រហែសរបស់មន្ត្រីជំនួយក្នុងការអនុវត្តរក្សាការពារ

ក្នុងនីតិវិធីរក្សាការពារ និងប្រកាសអន្តរក្រសួងស្តីពីនីតិវិធី នៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងការរឹបអូសចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី យើងឃើញមានសមសភាពស្ថាប័នដែលជាប់ពាក់ព័ន្ធជាច្រើនដែលទទួលបន្ទុកក្នុងការអនុវត្តក្នុងនោះរួមមាន ក្រឡាបញ្ជី អាជ្ញាធរមូលដ្ឋាន ភូមិ ឃុំ/សង្កាត់ ស្រុក/ខណ្ឌ រាជធានី/ខេត្ត រដ្ឋបាលសុរិយោដី ក្រសួង/មន្ទីរ ការិយាល័យ ក្រសួង/មន្ទីរសាធារណៈការ (ចំពោះនាវា) កងកម្លាំងប្រដាប់អាវុធ ជាពិសេសអាជ្ញាសាលា គឺទទួលបន្ទុកក្នុងការអនុវត្តដីកាសម្រេចរបស់តុលាការ។

[102] មាត្រា ២៤៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ៦ កក្កដា ២០០៦

[103] គេហ៍ទំព័រ freshnew http://m.freshnewsasia.com/index.php/en/localnews/226485-2022-01-03-05-26-24.html

ក្នុងពេលអនុវត្តសំណុំរឿងរក្សាការពារ ជានិច្ចជាកាលអាចលើកឡើងនូវអំពើហឹង្សារវាងមន្ត្រីជំនួយដែលទទួលបន្ទុកក្នុងការអនុវត្តរក្សាការពារ និងកូនបំណុលនៃការអនុវត្តជាយថាហេតុ ដោយមានការប្រតាយប្រទាប់គ្នា ឬពេលមន្ត្រីអនុវត្តចុះទៅ ដល់ទីតាំងនៃការអនុវត្ត កូនបំណុលមិនស្របតាម ឬស្ម័គ្រចិត្តដោយសន្តិវិធី ដែលតម្រូវឱ្យកងកម្លាំងសាធារណៈបើវិធានការបង្ខំឱ្យប្រគល់ ឬចាប់យកវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយប្រើកម្លាំងបាយជាដើម។ ក្នុងករណីមួយចំនួនគឺជាការធ្វេសប្រហែសរបស់មន្ត្រីជំនួយពេលចុះទៅអនុវត្តខ្វះខ្នាយមិនបានធ្វើរបាយការណ៍ ឬពេលមន្ត្រីជំនួយចុះអនុវត្តចូលលំនៅដ្ឋានរបស់កូនបំណុលដោយគ្មានការអនុញ្ញាត ឬធ្វើឱ្យបែកបាក់វត្ថុដែលជាកម្មវត្ថុនៃការចាត់ចែងរក្សាការពារ ឬវត្ថុដែលមិនមែនជាវត្ថុនៃការចាត់ចែងរក្សាការពារ។

ឧទាហរណ៍៖ អាជ្ញាសាលាចុះអនុវត្តដីកាសម្រេចរក្សាការពារ ដោយមានកងកម្លាំងសាធារណៈជាជំនួយ ចំពោះដី L1 ដែលហាមឃាត់ កូនបំណុលមិនឱ្យចាត់ចែង ធ្វើការសាងសង់ និងរុះរើសំណង់អាណាធិបតេយ្យចេញពីដីខាងលើ ជាបណ្ដោះអាសន្ន រហូតដល់មានការសម្រេចអំពីបណ្ដឹងអង្គសេចក្ដី ប៉ុន្តែកូនបំណុលមិនស្ម័គ្រចិត្តទៅតាមដីកាសម្រេចរបស់តុលាការនោះទេ ព្រមទាំងមានការប្រើប្រាស់កូនបំណុលនៃការអនុវត្តជេរប្រមាថ និងប្រើហឹង្សាទៅលើមន្ត្រីអនុវត្តទៀតផង។

ឧទាហរណ៍៖ សញ្ញាណក្នុងដីកាសម្រេចតម្រូវឱ្យអនុវត្តត្រឹមតែរថយន្តម៉ាកLEX570 ស្លាកលេខ១២៣៤ ពណ៌ខ្មៅចំនួនមួយគ្រឿង ប៉ុន្តែនៅពេលអនុវត្តបែរជាអនុវត្តខុសវត្ថុដែលជាកម្មវត្ថុដោយរឹបអូសរថយន្តម៉ាកTOYOTA ពណ៌ស ដែលនេះជាហេតុនាំឱ្យមានការឈ្លោះប្រកែកគ្នារវាងកូនបំណុល និងមន្ត្រីជំនួយក្នុងការអនុវត្តទៅវិញ។

## ១.៦ ការចាត់ចែងរក្សាការពារខុសអចលនវត្ថុ

ដោយហេតុនៅក្នុងសំណុំរឿងរដ្ឋប្បវេណីតុលាការអកម្ម មានន័យថាតុលាការពិនិត្យ និងសម្រេចសេចក្ដីផ្អែកទៅលើភស្តុតាងនៅពេលដែលគូភាគីដាក់មកតែប៉ុណ្ណោះ។ ហើយក្នុងសំណុំរឿងរក្សាការពារម្ចាស់បំណុលដាក់ពាក្យឱ្យរក្សាការពារ ដែលជាលក្ខខណ្ឌសារធាតុតុលាការគ្រាន់តែពិនិត្យអំពីសេចក្ដីបញ្ជាក់ដំបូង និងពិនិត្យអំពីទម្រង់ដែលច្បាប់បានកំណត់តុលាការអាចចេញដីកាសម្រេចចាត់ចែងរក្សាការពារបានហើយព្រោះដីកាសម្រេចធ្វើឡើងជាសម្ងាត់មិនឱ្យកូនបំណុលដឹងជាមុន ហើយវិធានរក្សាការពារនេះដែលគឺធ្វើឡើងក្នុងគោលបំណងរក្សាស្ថានភាពបច្ចុប្បន្ននៃវត្ថុរហូតដល់មានការសម្រេចអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ។ ដោយសារតែតុលាការពិនិត្យត្រឹមតែភស្តុតាង ហើយក្នុងករណីមួយចំនួនម្ចាស់បំណុលពិបាកយ៉ាងខ្លាំងក្នុងការសិក្សាស្វែងរកអត្តសញ្ញាណទ្រព្យសម្បត្តិរបស់កូនបំណុល ដើម្បីសម្រេចគោលបំណង និងលំបាកក្នុងការកំណត់អត្តសញ្ញាណនៃទ្រព្យសម្បត្តិនិងស្វែងរកអត្តសញ្ញាណរបស់កូនបំណុលខុសដោយប្រការណាមួយ ទ្រព្យសម្បត្តិនោះអាចជាកម្មសិទ្ធិរបស់តតិយជន ឬក្នុងករណីខ្លះកម្មវត្ថុនៃការចាត់ការពារនោះជាដីរបស់រដ្ឋ ដោយសារតែកូនបំណុលទុច្ចរិតបាន

ក្លែងបន្លំអំពីអត្តសញ្ញានៃវត្ថុ និងប្រវត្តិរូបរបស់ខ្លួន ជាអាទិ៍។ ហើយក្នុងករណីខ្លះម្ចាស់បំណុលបានស្វែងរក និងកំណត់អំពីអត្តសញ្ញាណនៃអចលនវត្ថុច្បាស់លាស់ហើយ ក៏ផលវិបាកអាចកើតមានដូចជាកម្មវត្ថុនៃការអនុវត្តត្រូវបានបាត់បង់ ឬផ្លាស់ប្តូរទីតាំង ឬបានផ្ទេរទៅបុគ្គលផ្សេង ឬក៏មិនមានការសហការ និងចូលរួមពីអាជ្ញាធរ ឬការសហការពីកូនបំណុល ជាអាទិ៍។ មិនត្រឹមតែប៉ុណ្ណោះក្នុងករណីមួយចំនួន ភូមិសាស្ត្រដែនដីនៃការគ្រប់គ្រងរដ្ឋបាលក្នុងតំបន់មួយចំនួនមានផ្ទៃដីធំ ដោយសារតែមានការបែងចែករដ្ឋបាលដែនដីពីរដ្ឋបាលថ្នាក់ជាតិ ដែលនេះវាគឺជាហេតុដែលនាំឱ្យបាត់បង់អត្តសញ្ញាណនៃអចលនវត្ថុ ឬមានការលំបាកក្នុងការស្រាវជ្រាវរបស់ភាគីម្ចាស់បំណុល។

ឧទាហរណ៍៖ ម្ចាស់បំណុលបានដាក់ពាក្យសុំឱ្យរក្សាការពារចំពោះដី L1 ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ១២៤១ ក្រោយមកតុលាការបានចេញដីសម្រេចរក្សាការពារចំពោះដី L1 តាមការស្នើសុំរបស់ភាគីម្ចាស់បំណុល។ ម្ចាស់បំណុលក៏បានដាក់ពាក្យសុំអនុវត្តរក្សាការពារចំពោះដី L1 ប៉ុន្តែនៅពេលដែលចុះទៅអនុវត្តដី L1 នោះគឺជាដីស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋ ដែលនេះបានធ្វើឱ្យខាតបង់ផលប្រយោជន៍ជាខ្លាំងរបស់ម្ចាស់បំណុល។

ឧទាហរណ៍៖ ដី L1 មានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់លេខ១២៣ ស្ថិតនៅខេត្តកណ្តាល ក្រោយមកម្ចាស់បំណុលបានដាក់ពាក្យសុំឱ្យរក្សាការពារចំពោះដី L1 មកសាលាដំបូងខេត្តកណ្តាល ដោយមានចៅក្រម ក ទទួលបន្ទុកសំណុំរឿង។ ប៉ុន្តែដី L1 ត្រូវបានការកាត់មករាជធានីភ្នំពេញមុនពេលចេញដីកាសម្រេច ដោយសារតែការកំណត់ព្រំប្រទល់ដែនដីរដ្ឋបាលពុំមានភាពច្បាស់លាស់។

## ផ្នែកទី២៖ ដំណោះស្រាយ

ការចាត់ចែងរក្សាការពារ គឺជានីតិវិធីពិសេសមួយ ដែលម្ចាស់បំណុលអាចដាក់ពាក្យសុំឱ្យរក្សាការពារទៅតុលាការដែលមានសមត្ថកិច្ចក្នុងគោលបំណងការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ខ្លួនមុនបណ្តឹងអង្គសេចក្តីបាន វាជាមធ្យោបាយសង្គ្រោះជាបណ្តោះអាសន្នដ៏ល្អមួយសម្រាប់ម្ចាស់បំណុល។ ទោះបីជាម្ចាស់បំណុល ឬអ្នកដាក់ពាក្យសុំបានសម្រេចគោលបំណងក្នុងការរក្សាការពារ និង បំពេញទៅតាមលក្ខខណ្ឌដែលច្បាប់បានកំណត់ក៏ដោយ ក៏បញ្ហាប្រឈមតែងតែជួបប្រទះជានិច្ចជាកាល ដោយមើលឃើញពីបញ្ហាដែលជួបប្រទះជានិច្ចជាកាលនេះហើយ និងដើម្បីជាការសម្រួលដល់ការអនុវត្ត រាជរដ្ឋាភិបាល និងស្ថាប័នមានសមត្ថកិច្ចបានយកចិត្តទុកដាក់ជាខ្លាំងប្រឹងប្រែងបង្កើតនូវលិខិតបទដ្ឋានគតិយុត្តនានាដែលជាប់ពាក់ព័ន្ធ និងជំរុញផ្សព្វផ្សាយច្បាប់ដែលពាក់ព័ន្ធជាសាធារណៈ និងបើកវគ្គសិក្ខាសាលាខ្លីៗជូនទៅដល់មន្ត្រីសាធារណៈដែលពាក់ព័ន្ធ។

## ២.១ ការបង្កើតលិខិតបទដ្ឋានគតិយុត្តឱ្យបានច្រើន

ដោយសារតែទំនាស់ផលប្រយោជន៍កើតឡើងជានិច្ចជាកាល តម្រូវការនៃច្បាប់ជាកត្តាចំបងសម្រួលដល់ការដោះស្រាយ និងដោយមានការយកចិត្តទុកដាក់ពីសំណាក់រាជរដ្ឋាភិបាល និងជាពិសេសស្ថាប័នមានសមត្ថកិច្ចក្រសួងយុត្តិធម៌ និងស្ថាប័នផ្សេងដែលជាប់ពាក់ព័ន្ធ បានខិតខំប្រឹងប្រែងបង្កើតនូវលិខិតបទដ្ឋានគតិយុត្តជាច្រើនដើម្បីបំពេញបន្ថែមក្នុងការអនុវត្តប្រកបដោយប្រសិទ្ធិភាពក្នុងនោះរួមមាន ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និងការរឹបអូសចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី, ប្រកាសស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ហើយនៅក្នុងឆ្នាំ២០០៨ ដោយសារកង្វះខាតនូវមន្ត្រីអាជ្ញាសាលា សាលាភូមិន្ទអាជ្ញាសាលាក៏ត្រូវបានបង្កើតឡើង ចំពោះលិខិតបទដ្ឋានគតិយុត្តដូចដែលបានរៀបរាប់ខាងលើនេះ គឺបង្កើតក្នុងគោលបំណងដើម្បីសម្រួលដល់ការចាត់ចែងរក្សាការពារ និងអនុវត្តចាត់ចែងរក្សាការពារ ប្រកបដោយប្រសិទ្ធិភាព និងភាពយុត្តិធម៌ និងជាការអភិវឌ្ឍន៍លើកកម្ពស់វិស័យច្បាប់ស៊ីវិលឱ្យកាន់តែមានភាពល្អប្រសើរជាលំដាប់ផងដែល។

## ២.២ ការផ្សព្វផ្សាយច្បាប់ជាសាធារណៈ

ដើម្បីលើកកម្ពស់វិស័យច្បាប់ឱ្យកាន់តែរីកចម្រើន ក្រសួងយុត្តិធម៌ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងស្ថាប័នមានសមត្ថកិច្ចបានផ្សព្វផ្សាយច្បាប់ជាច្រើន ជាពិសេសនោះគឺដំណើរការនីតិវិធីក្នុងរឿងក្តីរដ្ឋប្បវេណីតាមរយៈសិក្ខាសាលាអនឡាយ ទូរទស្សន៍ វិទ្យុ និងបណ្តាញទំនាក់ទំនងសង្គម ជាអាទិ៍ ។ ចំពោះការផ្សព្វផ្សាយច្បាប់ជាសាធារណៈជូនដល់ប្រជាពលរដ្ឋក្នុងការសិក្សាស្វែងយល់អំពីដំណើរ ឬលំហូនីតិវិធីនៃច្បាប់ ហើយនៅពេលប្រជាពលរដ្ឋគាត់មានចំណេះដឹងផ្នែកច្បាប់ ឬយល់ដឹងពីច្បាប់ហើយនោះ អាចនិយាយបានថានៅពេលដែលវិវាទ ឬទំនាស់ផលប្រយោជន៍កើតមានឡើងនោះ គាត់អាចដោះស្រាយវិវាទដោយសន្តិវិធី ឬក៏មន្ត្រីមានសមត្ថកិច្ចចុះទៅអនុវត្តដីកាសម្រេចរបស់តុលាការ គាត់ស្ម័គ្រចិត្តស្របតាមជាដើម។

## ២.៣ ការជ្រើសសិស្សអាជ្ញាសាលា និងកិច្ចសហការមន្ត្រីជំនួយអនុវត្តរក្សាការពារ

ក្នុងឆ្នាំ២០០៨ ដោយឃើញពីកង្វះខាតនូវមន្ត្រីអាជ្ញាសាលា សាលាភូមិន្ទអាជ្ញាសាលា ក៏ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ១១៦ អនក្រ.ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៨ ហើយសាលាភូមិន្ទអាជ្ញាសាលានេះ ស្ថិតនៅក្នុងរចនាសម្ព័ន្ធនៃការគ្រប់គ្រង និង ដឹកនាំផ្ទាល់របស់រាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការដែលជាគ្រឹះស្ថានសាធារណៈរដ្ឋបាល មានស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុ ដែលត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខនស/រកក/០១០៥/០១៩ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៥។ ដើម្បីបន្តសកម្មភាព និងបំពេញនូវវិជ្ជាជីវៈអាជ្ញាសាលា ដោយអនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណី ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** រដ្ឋមន្ត្រីទទួល

បន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សារាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ បានចេញប្រកាសលេខ១៥៩ ប្រក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការប្រឡងប្រជែងជ្រើសរើសសិស្សអាជ្ញាសាលាជំនាន់ទី១នៃរាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ ក្នុងខែធ្នូ ឆ្នាំ២០១២ ដោយមានបេក្ខជនជ័យលាភីចំនួន២៦រូប ស្ត្រី២រូប តាមប្រកាសលេខ១៨ ប្រក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការតែងតាំងសិស្សអាជ្ញាសាលាជំនាន់ទី១ នៃរាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ ហើយនាពេលថ្មីៗនេះរាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការបានប្រកាសឱ្យមានការប្រឡងប្រជែងជ្រើសរើសសិស្សអាជ្ញាសាលា ជំនាន់ទី២ ដែលប្រព្រឹត្តទៅនៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០២២ មានបេក្ខជនជ័យលាភីចំនួន២៨រូប ស្ត្រី៦រូប ប្រកាសលេខ០៥៩ កយ ប្រក/២២ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ របស់ក្រសួងយុត្តិធម៌ ស្តីពីការតែងតាំងសិស្សអាជ្ញាសាលាជំនាន់ទី២ នៃរាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ។

ដោយឃើញពីផលវិបាករបស់អាជ្ញាសាលា ដែលកំពុងតែជួបប្រទះយើងខ្ញុំយល់ថាដើម្បីធ្វើឱ្យកិច្ចការរបស់អាជ្ញាសាលាប្រព្រឹត្តទៅមានភាពល្អប្រសើរ គឺត្រូវមានការចូលរួមសហការពីស្ថាប័នដែលពាក់ព័ន្ធ ដូចជាកងកម្លាំងសាធារណៈជាដើម ក្នុងការជួយសម្រួលដល់ការអនុវត្តនីតិវិធីដែលច្បាប់បានកំណត់។ មិនត្រឹមតែប៉ុណ្ណោះយើងខ្ញុំសូមគាំទ្រនូវការបង្កើតឱ្យមាន ច្បាប់ស្តីពីលក្ខន្តិកៈអាជ្ញាសាលា ឱ្យកាន់តែមានភាពឆាប់រហ័ស និងមានការបណ្តុះបណ្តាលជាបន្តបន្ទាប់នូវសិស្សអាជ្ញាសាលា ដើម្បីឱ្យក្លាយជាមន្ត្រីអាជ្ញាសាលាដ៏មានជំនាញក្នុងការបំពេញកិច្ចការវិជ្ជាជីវៈនៅស្ថាប័នតុលាការសាលាដំបូងរាជធានី-ខេត្ត។ ដូចដែលបានរៀបរាប់ខាងលើនេះដោយសារតែបច្ចុប្បន្ន មន្ត្រីអាជ្ញាសាលានៅមានការខ្វះខាតច្រើន ហើយសាលាដំបូងមួយចំនួននៅមិនទាន់មានមន្ត្រីអាជ្ញាសាលាដើម្បីអនុវត្តកិច្ចនីតិវិធីដែលជាកិច្ចការរបស់អាជ្ញាសាលាត្រូវធ្វើនៅឡើយទេ។ ម្យ៉ាងវិញទៀតសូមសំណូមពរឱ្យមានការផ្សព្វផ្សាយណែនាំ និងពន្យល់បន្ថែមចំពោះសាធារណៈជនឱ្យបានយល់ដឹងកាន់តែច្បាស់ផងដែរអំពីតួនាទី ភារកិច្ចរបស់អាជ្ញាសាលាក្នុងការអនុវត្តដែលស្របទៅនឹងច្បាប់ ដើម្បីការពារនូវផលប្រយោជន៍របស់បុគ្គលដែលជាម្ចាស់បំណុលនៃការអនុវត្ត។

## ២.៤ ការកំណត់សមត្ថកិច្ចរបស់ព្រះរាជអាជ្ញា និងអាជ្ញាសាលា

ទោះបីជាបច្ចុប្បន្ននេះអាជ្ញាសាលា ត្រូវបានបង្កើតឡើងដោយទទួលបន្ទុកក្នុងការបំពេញភារកិច្ចក៏ដោយក៏មានបញ្ហាប្រឈម និងការប្រទាំងប្រទិស និងភាពស្មុគស្មាញនៅតែមានជាក់ជាមិនខានដោយយើងអាចមើលឃើញសំណុំរឿងរក្សាការពារ និងសំណុំរឿងអនុវត្តដោយបង្ខំមួយចំនួន ស្ថិតនៅក្នុងសមត្ថកិច្ចរបស់ ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ដែលនេះហើយគឺជាភាពស្មុគស្មាញ និងចំណាយពេលវេលាក្នុងការអនុវត្ត ដែលផ្ទុយពីគោលគំនិតនៃការចាត់ចែងរក្សាការពារ ដែលគឺជានីតិវិធីបង្កើតឱ្យមានភាពឆាប់រហ័សដើម្បីសម្រួលដល់ម្ចាស់បំណុល

ក្នុងការអនុវត្តនៅពេលក្រោយ។ ដើម្បីបន្តនីតិវិធីទៅមុខបានជនដែលជាប់ពាក់ព័ន្ធនិងផលប្រយោជន៍អាចធ្វើការដាក់ពាក្យស្នើសុំទៅតុលាការដើម្បី ផ្លាស់ប្តូរ ឬផ្ទេរសមត្ថកិច្ចក្នុងការអនុវត្តពីព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង មកសមត្ថកិច្ចដែលទទួលបន្ទុកអនុវត្តដោយអាជ្ញាសាលា ឬ មានដីកាសម្រេចផ្ទេរសំណុំរឿងពីសមត្ថកិច្ចរបស់ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង មកអាជ្ញាសាលាដែលទទួលបន្ទុកក្នុងការអនុវត្តបន្ត។

## ២.៥ ការយកចិត្តទុកដាក់របស់មន្ត្រីជំនួយក្នុងការអនុវត្តរក្សាការពារ

ចំពោះអំពើដែលកើតមានឡើងរបស់មន្ត្រីជំនួយក្នុងការអនុវត្តមានការធ្វេសប្រហែស អាចជាកំហុសរបស់មន្ត្រីដែលទទួលបន្ទុកអនុវត្តនៅពេលដែលខ្លួនបំពេញតួនាទី ឬមានកំហុសអនុវត្តខុសចំពោះវត្ថុនៃការអនុវត្ត ឬ អាចដោយសារតែការយល់ដឹងអំពីផ្នែកច្បាប់របស់កូនបំណុលនៅមានកម្រិតជាដើម។ ដើម្បីចៀសវាងអំពីការធ្វេសប្រហែសរបស់មន្ត្រីជំនួយក្នុងការអនុវត្តសំណុំរឿងរក្សាការពារ និងពង្រឹងសមត្ថភាពរបស់មន្ត្រីជំនួយក្នុងការអនុវត្តរក្សាការពារ យើងខ្ញុំស្នើសុំដល់ក្រសួងយុត្តិធម៌ ចាត់តាំងអ្នកជំនាញផ្នែកច្បាប់បើកវគ្គសិក្សាបណ្តុះបណ្តាលខ្លីៗ ជូនចំពោះមន្ត្រីជំនួយដែលទទួលបន្ទុកក្នុងការអនុវត្តដោយមានការចូលផ្ទាល់ ឬ តាមរយៈប្រព័ន្ធអនឡាញ ឬ គួរតែបង្កើតឱ្យមានសិក្ខាសាលា ឬ បទបង្ហាញឱ្យបានច្រើនតាមដែលអាចធ្វើទៅបានទាក់ទងនឹងផ្នែកច្បាប់ ជាពិសេសគឺសិទ្ធិអំណាច ភារៈកិច្ចក្នុងការអនុវត្តដីកាសម្រេចរក្សាការពាររបស់មន្ត្រីជំនួយដែលទទួលបន្ទុកក្នុងការអនុវត្តនោះ។

## ២.៦ ការកំណត់ឱ្យបានច្បាស់អត្តសញ្ញាណកម្មវត្ថុនៃការចាត់ចែងរក្សាការពារ

ស្របតាមក្រមនីតិវិធីរដ្ឋប្បវេណីស្តីពីការចាត់ចែងរក្សាការពារ ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍អាចដាក់ពាក្យសុំឱ្យរក្សាការពារ ក្នុងគោលបំណងការពារផលប្រយោជន៍ស្របច្បាប់របស់ខ្លួន។ ប៉ុន្តែទោះបីវិធានរក្សាការពារបើកសិទ្ធិឱ្យក៏ពិតមែន ប៉ុន្តែម្ចាស់បំណុលពិតជាមានការលំបាកជាខ្លាំងក្នុងស្វែងរកអត្តសញ្ញាណវត្ថុដែលជាកម្មសទ្ធិរបស់កូនបំណុល ដោយមើលឃើញពីការលំបាកក្នុងការសិក្សាស្វែងរកអំពីអត្តសញ្ញាណនៃអចលនវត្ថុនេះហើយ យើងខ្ញុំស្នើសុំដល់ក្រសួងស្ថាប័នមានសមត្ថកិច្ចមេត្តាជួយសម្រួលដល់ម្ចាស់បំណុលនៅពេលដែលគាត់ទៅសុំពិនិត្យមើលអំពីបញ្ជីអត្តសញ្ញាណនៃដី ដើម្បីជាភាពងាយស្រួលរបស់ម្ចាស់បំណុលកំណត់អំពីអត្តញ្ញាណនៃដីនោះ ថាតើជាដីរបស់កូនបំណុលមែនដែរ ឬទេ។ ចំពោះការស្នើសុំនេះ គឺដើម្បីជួយសម្រួលដល់ម្ចាស់ក្នុងករណីដែលម្ចាស់បំណុលគ្មានមូលដ្ឋានក្នុងការកំណត់អំពីអត្តសញ្ញាណនៃដី ដែលវាជាហេតុនាំឱ្យម្ចាស់បំណុលអាចដាក់រក្សាការពារលើដី របស់តតិយជន ឬអាចជាដីរបស់រដ្ឋ ជាអាទិ៍។ ដូចដែលបានលើកឡើងរួចមកហើយប្រសិនបើក្នុងករណី ភូមិសាស្ត្រដែនដីនៃការគ្រប់គ្រងមានភាពប្រែប្រួលនិងមានភាពមិនច្បាស់លាស់ បើចុងចម្លើយតវ៉ាអំពីសមត្ថកិច្ចនៃសាលាដំបូងខេត្តកណ្តាល អាចនាំឱ្យសាលាដំបូងខេត្តកណ្តាលមិនអាចអនុវត្ត

សិទ្ធិជម្រះក្តីបានឡើយ ហេតុនេះដើម្បីអាចបន្តនីតិវិធី កូនបំណុល អាចដាក់ពាក្យស្នើសុំទៅតុលាការកំពូលឱ្យកំណត់សាលាដំបូងណាមួយទទួលបន្ទុកដោះស្រាយរឿងនេះ ដូចជាសាលាដំបូងខេត្តកណ្តាល ឬសាលាដំបូងរាជធានីភ្នំពេញ ដោយដីកាសម្រេច ជាអាទិ៍។

ម៉្យាងដើម្បីធានាគោលការណ៍នៃភាពស្របច្បាប់ និងបញ្ជាក់អំពីអត្តសញ្ញាណនៃអចលនវត្ថុដែលត្រូវបានរក្សាការពារតម្រូវឱ្យមានការផ្ទុកផ្តាក់ ហើយស្ថាប័នដែលទទួលការផ្ទុកផ្តាក់សំដៅដល់ ស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីដែលត្រូវបានកំណត់ផ្សេងពីគ្នាទៅលើអចលនវត្ថុដែលបានចុះបញ្ជី និងអចលនវត្ថុដែលមិនទាន់ចុះបញ្ជី ដែលច្បាប់បានកំណត់សិទ្ធិ និងកាតព្វកិច្ចអំពីការចុះបញ្ជីនោះ[104]។

[104] ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីទាក់ទង នឹងការចាត់ចែងរក្សាការពារ និងការរឹបអូសចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី, លេខ ២១៤ ប្រក.ដសន, ចុះថ្ងៃទី ២១ វិច្ឆិកា ២០១៤

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីយើងខ្ញុំបានធ្វើការសិក្សា និងស្រាវជ្រាវនូវប្រធានបទ ការចាត់ចែងរក្សាការពារលើអចនវត្ថុរួចមកយើងខ្ញុំ សម្មត់ថាប្រធានបទខាងលើនេះ គឺជានីតិវិធីមួយដែលមានលក្ខណៈជាបណ្តោះអាសន្ន ដែលមានគោលបំណងការពារនូវសិទ្ធិ និងផលប្រយោជន៍របស់ម្ចាស់បំណុលដោយស្របច្បាប់ នៅពេលដែលមានការព្រួយបារម្ភថា ការអនុវត្តដោយបង្ខំ ឬការសម្រេចគោលបំណងរបស់ម្ចាស់បំណុលមិនអាចធ្វើបានដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់កូនបំណុល ឬប្រសិនបើមានការបារម្ភថានឹងមានការខូចខាត ឬគ្រោះថ្នាក់បន្ទាន់ដល់ឋានៈរបស់ភាគីណាមួយដោយសារមានវិវាទអំពីទំនាក់ទំនងនៃសិទ្ធិ។ ទន្ទឹមនឹងនេះទោះបីជានីតិវិធីចាត់ចែងរក្សាការពារ ជានីតិវិធីមួយដែលជួយការពារនូវការខូចខាតផលប្រយោជន៍រវាងម្ចាស់បំណុល និងកូនបំណុលក៏ដោយ ក៏នីតិវិធីនេះនៅតែមានគុណសម្បត្តិ និងគុណវិបត្តិរួមមកជាមួយផងដែល។ ចំពោះគុណសម្បត្តិនៃការចាត់ចែងរក្សាការពារលើអចលនវត្ថុ គឺជាការបង្កើតឱ្យមានយន្តការសង្គ្រោះបណ្តោះអាសន្នទម្រាំសិទ្ធិត្រូវបានសម្រេចជាស្ថាពរ ដោយសាលក្រម ឬសាលដីកា ក៏ដូចជាដើម្បីធានាឱ្យបាននូវស្ថានភាពដើមនៃទ្រព្យសម្បត្តិរបស់កូនបំណុល។ល។ នីតិវិធីចាត់ចែងរក្សាការពារគឺ តម្រូវឱ្យម្ចាស់បំណុលដាក់ពាក្យសុំឱ្យតុលាការធ្វើការចាត់ចែងរក្សាការពារ ឬ លើកពាក្យសុំចោល។ បន្ទាប់មកបើតុលាការ ចេញដីកាសម្រេចរក្សាការពារ ម្ចាស់បំណុលត្រូវទៅដាក់ពាក្យសុំអនុវត្តរក្សាការពារបន្តទៀតដើម្បីយកទៅអនុវត្ត។ ប្រសិនបើ មានភាគីណាម្ខាងពុំសុខចិត្ត អាចធ្វើការសុំដាក់ពាក្យតវ៉ា ឬ ធ្វើបណ្តឹងជំទាស់បាន។ ជាក់ស្តែង នីតិវិធីចាត់ចែងរក្សាការពារមានលក្ខណៈរហ័ស បន្ថែមពីលើនេះទៅទៀត នីតិវិធីនេះពិតជាបានជួយដល់ ផលប្រយោជន៍ ការទាមទារនូវសិទ្ធិ និងកាត់បន្ថយនូវការកង្វល់ដល់ម្ចាស់បំណុលបានយ៉ាងច្រើន ដោយសារតែភាពឆាប់រហ័ស និងសម្ងាត់របស់និតិវិធី។ ចំពោះគុណវិបត្តិរបស់វាវិញមានដូចជា ចំពោះកូនបំណុលក្នុងករណីដែលដីកាសម្រេចរក្សាការពារតុលាការធ្វើឡើងដោយមិនឱ្យម្ចាស់ បំណុលដាក់ប្រាតិភោគ ដោយសារតែបើគ្មានប្រាតិភោគទេកូនបំណុល និងមានការលំបាកក្នុងការទាមទារសំណងនៃការខូចខាតដែលកើតឡើងដោយសារដីកាសម្រេចរក្សាការពារ បើទោះជាកូនបំណុលអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនតាមរយៈអំពើអនីត្យានុកូល ដែលមានចែងក្នុងមាត្រា៧៤៣ នៃក្រមរដ្ឋប្បវេណីក៏ដោយ។ ហើយប្រាតិភោគនេះ មិនមែនតុលាការធ្វើឡើងតែចំពោះម្ចាស់បំណុលប៉ុណ្ណោះទេ ថែមទាំងកូនបំណុលផងដែរ នៅពេលដែលតុលាការចេញដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារ ។ និយាយជារួមទៅនីតិវិធីនៃការចាត់ចែងរក្សាការពារនេះ មិនមែនជានីតិវិធីដែល ការពារតែផលប្រយោជន៍របស់ម្ចាស់បំណុលតែម្ខាងនោះទេ ព្រោះថានីតិវិធី ឬ ច្បាប់ផ្សេងៗ ដែលគេបង្កើតឡើងមកសុទ្ធសឹងតែគិតគូពីផលប្រយោជន៍បុគ្គលទូទៅ។ គុណវិបត្តិមួយទៀតនៃការចាត់ចែងរក្សាការពារគឺ ការតវ៉ាចំពោះដីការសម្រេចរក្សាការពារ បណ្តឹងជំទាស់

ចំពោះដីកាសម្រេចលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារជាអាទិ៍។ លើសពីនេះទៅទៀតនៅពេលដែលអាជ្ញាសាលាចុះអនុវត្តគឺពិតជាមានការលំបាកណាស់ ព្រោះថាអ្នកដែលកាន់កាប់នូវទ្រព្យសម្បត្តិ ដែលជាកម្មវត្ថុនៃការចាត់ចែងរក្សាការពារ អាចនឹងធ្វើការតបតប្រឆាំងនឹងការអនុវត្ត។ ដូច្នេះដើម្បីធានាក្នុងការបំពេញតួនាទីរបស់ខ្លួនអាជ្ញាសាលាអាចប្រើកម្លាំង សុំជំនួយពីនគរបាល ឬកងកម្លាំងផ្សេងទៀត ដែលមានសមត្ថកិច្ចដើម្បីបំបាត់នូវការប្រឆាំងនោះបាន។

សរុបសេចក្តីមក ការចាត់ចែងរក្សាការពារលើអចលនវត្ថុ បានផ្តល់គុណសម្បត្តិជាច្រើន ព្រោះថាវាជានីតិវិធីដែលមានលក្ខណៈជាបណ្តោះអាសន្ន និងមានភាពឆាប់រហ័ស ដោយមិនចាំបាច់រង់ចាំរហូតដល់សាលក្រម ឬសាលដីកាចូលជាស្ថាពរ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ភាគី ដែលអាចនឹងទទួលនូវការខូចខាត ឬខាតបង់ដែលអាចនឹងកើតឡើងជាក់ជាពុំខាន បើមិនប្រញាប់ចាត់ចែងឱ្យទាន់ពេលវេលានោះទេ។ ទន្ទឹមនឹងនេះ ការចាត់ចែងរក្សាការពារលើអចលនវត្ថុ ក៏បានផ្តល់នូវផលវិបាកមួយចំនួនដែរដូចជា តុលាការចេញសេចក្តីសម្រេចដោយមិនបានឱ្យម្ចាស់បំណុលដាក់ប្រាតិភោគ ហេតុនេះនៅពេលកូនបំណុល ទាមទារសំណងនូវការខូចខាត នោះកូនបំណុលនឹងមានការលំបាកក្នុងការទាមទារ។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបានសិក្សា និងស្រាវជ្រាវយ៉ាងស៊ីជម្រៅអំពីប្រធានបទស្តីពី ការចាត់ចែងរក្សាការពារលើអចលនវត្ថុ រយៈពេលកន្លងមកនេះ យើងខ្ញុំយល់ឃើញថា ប្រធានបទនេះជាក់ស្តែងពិតជាមានចំណុចលំបាកច្រើនដែលតម្រូវឱ្យអ្នកសិក្សាផ្នែកច្បាប់ សិស្ស និស្សិត អ្នកអនុវត្តច្បាប់ និងសាធារណៈជនគ្រប់មជ្ឈដ្ឋាន គួរគប្បីស្វែងយល់ និងចេះឱ្យបានច្បាស់លាស់អំពីនីតិវិធីនេះ ដើម្បីពង្រឹងសមត្ថភាព និងជាប្រយោជន៍សម្រាប់ខ្លួនឯងនាពេលអនាគត។

ទន្ទឹមនឹងនេះយើងខ្ញុំក៏បានសង្កេតឃើញថា មានប្រជាពលរដ្ឋជាច្រើនដែលបានជួបប្រទះនូវបញ្ហាដែលទាក់ទងការទាមទារ ឬ ការទាមទារនូវសិទ្ធិ ដោយសារតែកូនបំណុលមានចេតនាចង់គេចវេសមិនព្រមទទួលខុសត្រូវ ដែលបង្កទៅជាវិវាទរវាងម្ចាស់បំណុល និងកូនបំណុល។ ចំពោះបញ្ហានេះផងដែរ ម្ចាស់បំណុលគួរតែជ្រើសរើសយកនីតិវិធីនៃការចាត់ចែងរក្សាការពារយកមកអនុវត្ត បើធៀបទៅនឹងបណ្តឹងអង្គសេចក្តី និង នីតិវិធីអនុវត្តដោយបង្ខំ។ ព្រោះថាបណ្តឹងអង្គសេចក្តីប្រើរយៈពេលយូរ បើគិតចាប់ពីពេលដាក់ពាក្យបណ្តឹងរហូតដល់ពេលចេញសាលក្រម និងសាលក្រមចូលជាស្ថាពរ។ ម្យ៉ាងក្នុងអំឡុងពេលដំណើរការនីតិវិធីបណ្តឹង បើសិនកូនបំណុលផ្ទេរទ្រព្យសម្បត្តិរបស់គាត់ទៅឱ្យតតិយជនតាមទំនើងចិត្តនោះ ទោះជាម្ចាស់បំណុលបានឈ្នះក្តីក៏ដោយក៏មិនអាចអនុវត្តដោយបង្ខំបានដែរ។ ប៉ុន្តែក្រឡេកទៅមើលសង្គមជាក់ស្តែង មានប្រជាជនតិចតួចស្តួចស្តើងណាស់ដែលយល់ដឹងអំពីនីតិវិធីចាត់ចែងរក្សាការពារ។ ដោយសារការយល់ដឹង ចំពោះការវិវត្តន៍ទៅលើច្បាប់នាពេលបច្ចុប្បន្ននូវមានកម្រិត យើងខ្ញុំសូមចូលរួមផ្តល់នូវមតិ និងយោបល់មួយចំនួន ក្នុងគោលបំណងដើម្បីជួយដល់សង្គមជាតិទាំងមូល សិស្ស និស្សិត អ្នកសិក្សាផ្នែកច្បាប់ និងប្រជាពលរដ្ឋនូវចំណុចមួយចំនួនដូចជា៖

ចូលរួមបង្កើត និងពង្រីកការផ្សព្វផ្សាយអំពីប្រព័ន្ធច្បាប់ឱ្យបានច្រើនទាំងនីតិវិធីក្នុងរឿងក្តីរដ្ឋប្បវេណី និងរឿងក្តីព្រហ្មទណ្ឌ តាមរយៈទូរទស្សន៍ វិទ្យុ ឬបណ្តាញសង្គមផ្សព្វផ្សាយផ្សេងៗ។

ស្ថាប័នមានសមត្ថកិច្ច ឬ អ្នកជំនាញផ្នែកច្បាប់គួរតែបង្កើតឱ្យមានសិក្ខាសិលា ឬបទបង្ហាញទាក់ទងឱ្យបានច្រើន។

# ឯកសារយោង

# ឯកសារយោង


- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៩៣
- ក្រមនីតិវិធីរដ្ឋប្បវេណី ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦
- ក្រមរដ្ឋប្បវេណី ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦
- សេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ និងភាគ២
  ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ រៀបចំដោយក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៨
- សេចក្ដីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៧
- ច្បាប់ស្ដីពី នីតិវិធីរដ្ឋប្បវេណីមិនមែនជាបណ្ដឹង ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០
- ច្បាប់ស្ដីពី នីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១០
- ប្រកាសអន្តរក្រសួងស្ដីពីនីតិវិធីនៃការចុះបញ្ជីទាក់ទង នឹងការចាត់ចែងរក្សាការពារ និងការរឹបអូស ចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី, លេខ២១៤ ប្រក.ដសន, ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤
- សន្ទានុក្រមពាក្យច្បាប់ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណីរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០០៧
- សៀវភៅមេរៀននីតិវិធីរដ្ឋប្បវេណី របស់លោកសាស្ត្រាចារ្យ អ៊ីវ ប៉ូលី
- សៀវភៅមេរៀននីតិវិធីរដ្ឋប្បវេណី របស់លោកសាស្ត្រាចារ្យ ហេង ប៉ូរ៉ា
- មេរៀននីតិវិធីចាត់ចែងរក្សាការពារ របស់លោក វ៉ាន់ សុបញ្ញា ,សិស្សចៅក្រមជំនាន់ទី៧
- គេហទំព័រ freshnew http://m.freshnewsasia.com/index.php/en/localnews/226485-2022-01-03-05-26-24.htm
- គេហទំព័រ ក្រសួងយុត្តិធម៌ https://t.me/mojcambodianews/17010

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

- ឧបសម្ព័ន្ធទី១៖ ក្រមនីតិវិធីរដ្ឋប្បវេណី គន្ថីទី៧ ស្តីពីការចាត់ចែងរក្សាការពារ
  ប្រកាសឱ្យប្រើថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦
- ឧបសម្ព័ន្ធទី២៖ ការអនុវត្តជាក់ស្តែងសំណុំរឿងរក្សាការពាររបស់សាលាដំបូងរាជធានីភ្នំពេញ
- ឧបសម្ព័ន្ធទី៣៖ ការអនុវត្តជាក់ស្តែងសំណុំរឿងរក្សាការពាររបស់សាលាឧទ្ធរណ៍រាជធានីភ្នំពេញ
- ឧបសម្ព័ន្ធទី៤៖ កំណត់ហេតុ ស្តីពីការចុះអនុវត្តដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន
  របស់អាជ្ញាសាលាសាលាដំបូងរាជធានីភ្នំពេញ
- ឧបសម្ព័ន្ធទី៥៖ ប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីទាក់ទងនឹងការចាត់ចែងរក្សាការពារ និង
  ការរឹបអូសចំពោះអចលនវត្ថុដែលមិនទាន់បានចុះបញ្ជី ចុះថ្ងៃទីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤
- ឧបសម្ព័ន្ធទី៦៖ សេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា ឆ្នាំ២០១២